[៩១៥] ចក្កវត្តិសត្តោ លក្ខណសមន្នាគតោ ចក្កវត្តិសត្តោ ពោធិសត្តោតិ ។ អាមន្តា ។ យាទិសោ ពោធិសត្តស្ស បុព្វយោគោ បុព្វចរិយា ធម្មក្ខានំ ធម្មទេសនា តាទិសោ ចក្កវត្តិសត្តស្ស បុព្វយោគោ បុព្វចរិយា ធម្មក្ខានំ ធម្មទេសនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩១៦] យថា ពោធិសត្តស្ស ជាយមានស្ស ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សា ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ទេវា បឋមំ បដិគ្គណ្ហន្តិ បច្ឆា មនុស្សាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩១៧] យថា ពោធិសត្តស្ស ជាយមានស្ស ចត្តារោ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ អត្តមនា ទេវិ ហោហិ មហេសក្ខោ តវ បុត្តោ ឧប្បន្នោតិ ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ចត្តារោ ទេវបុត្តា បដិគ្គហេត្វា មាតុ បុរតោ ឋបេន្តិ

[៩១៤] ពោធិសត្វ ប្រកបដោយលក្ខណៈឬ ។ អើ ។ ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថាពោធិសត្វឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩១៥] ចក្កវត្តិសត្វ ប្រកបដោយលក្ខណៈ ចុះចក្កវត្តិសត្វ ហៅថាពោធិសត្វឬ ។ អើ ។ បុព្វយោគៈ បុព្វចរិយា ការពោលធម៌ ការសម្តែងធម៌ របស់ពោធិសត្វ យ៉ាងណា បុព្វយោគៈ បុព្វចរិយា ការពោលធម៌ ការសម្តែងធម៌ របស់ចក្កវត្តិសត្វ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩១៦] កាលពោធិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ពួកទេវតាទទួលមុន ពួកមនុស្សទទួលក្រោយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩១៧] កាលពោធិសត្វប្រសូត ទេវបុត្រទាំង ៤ ទទួលហើយតម្កល់ទុក ក្នុងទីចំពោះមុខនៃព្រះមាតាថា បពិត្រនាងទេវី ព្រះនាងចូរត្រេកអរថា បុត្ររបស់នាង មានស័ក្តិធំ កើតហើយ យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទេវបុត្រទាំង ៤ ទទួលហើយតម្កល់ទុក ក្នុងទីចំពោះមុខនៃព្រះមាតាថា

អត្តមនា ទេវិ ហោហិ មហេសក្ខោ តវ បុត្តោ ឧប្បន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៨] យថា ពោធិសត្តស្ស ជាយមានស្ស ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ពោធិសត្តស្ស ឧ-ទកកិច្ចំ ករោន្តិ មាតុ ច ឯវមេវ ចក្កវត្តិសត្តស្ស ជាយមានស្ស ទ្វេ ឧទកស្ស ធារា អន្តលិក្ខា បាតុភវន្តិ ឯកា សីតស្ស ឯកា ឧណ្ហស្ស យេន ចក្កវត្តិសត្តស្ស ឧទកកិច្ចំ ករោន្តិ មាតុ ចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៩] យថា សម្បតិជាតោ ពោធិសត្តោ ស-មេហិ បាទេហិ បតិដ្ឋហិត្វា ឧត្តរេន អភិមុខោ សត្ត-បទវីតិហារេ គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយមានេ សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទា-និ បុនព្ភវោតិ ឯវមេវ សម្បតិជាតោ ចក្កវត្តិសត្តោ

បពិត្រនាងទេវី ព្រះនាងចូរត្រេកអរថា បុត្ររបស់នាង មានស័ក្តិធំ កើតហើយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥១៨] ពោធិសត្វប្រសូត ទនៃទឹក ២ គឺទនៃទឹកត្រជាក់ ១ ទនៃទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះព្រះពោធិសត្វផង ចំពោះព្រះមាតាផង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ទនៃទឹក ២ គឺទនៃទឹកត្រជាក់ ១ ទនៃទឹកក្តៅ ១ ធ្លាក់មកប្រាកដអំពីអាកាស ធ្វើកិច្ចជម្រះដោយទឹក ចំពោះចក្កវត្តិសត្វផង ចំពោះព្រះមាតាផង ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥១៩] ព្រះពោធិសត្វប្រសូតមកភ្លាម ជាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅរកទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលឆ្នើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះ ជាជាតិទីបំផុត (របស់អញ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ យ៉ាងណា ចក្កវត្តិសត្វប្រសូតមកភ្លាម

សមេហិ ចានេហិ បតិដ្ឋហិត្វា ឧត្តរេន អភិមុខោ សត្តបទវីតិហារេ គច្ឆតិ សេតម្ហិ ឆត្តេ អនុធារិយ-មានេ សព្វា ច ទិសា វិលោកេតិ អាសភិញ្ច វាចំ ភាសតិ អគ្គោហមស្មិ លោកស្ស ជេដ្ឋោហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨២០] យថា ពោធិសត្តស្ស ជាយមានស្ស មហតោ អាលោកស្ស មហតោ ឱភាសស្ស មហ-តោ ភូមិចាលស្ស បាតុភាវោ ហោតិ ឯវមេវ ចក្ក-វត្តិសត្តស្ស ជាយមានស្ស មហតោ អាលោកស្ស មហតោ ឱភាសស្ស មហតោ ភូមិចាលស្ស បាតុភា-វោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨២១] យថា ពោធិសត្តស្ស បកតិកាយោ សមន្តា ព្យាមំ ឱភាសតិ ឯវមេវ ចក្កវត្តិសត្តស្ស បកតិកាយោ សមន្តា ព្យាមំ ឱភាសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដាន់ដោយព្រះបាទដ៏ស្មើ មានមុខបែរទៅរកទិសខាងជើង ឈានទៅ ៧ ជំហាន កាលពួកទេវតាបាំងស្វេតច្ឆត្រ ក៏រមិលមើលសព្វទិស បន្លឺឡើងនូវអាសភិវាចាថា អញជាបុគ្គលឆ្នើមរបស់លោក អញជាបុគ្គលច្បងរបស់លោក អញជាបុគ្គលប្រសើររបស់លោក នេះ ជាជាតិទីបំផុត (របស់អញ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២០] កាលព្រះពោធិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីដ៏ខ្លាំង យ៉ាងណា កាលចក្កវត្តិសត្វប្រសូត ការកើតឡើងប្រាកដ នៃពន្លឺដ៏ធំ នៃរស្មីដ៏ធំ នៃការកម្រើកញាប់ញ័រផែនដីដ៏ខ្លាំង ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២១] កាយប្រក្រតី របស់ពោធិសត្វ រមែងភ្លឺទៅមួយព្យាមដោយជុំវិញ យ៉ាងណា កាយប្រក្រតី របស់ចក្កវត្តិសត្វ រមែងភ្លឺទៅមួយព្យាមដោយជុំវិញ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤២២] យថា ពោធិសត្តោ មហាសុបិនំ បស្សិ ឯវមេវ ចក្កវត្តិសត្តោ មហាសុបិនំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៣] ន វត្តព្វំ លក្ខណសមន្នាគតោ ពោធិ-សត្តោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ទ្វត្តឹសិមានិ ភិក្ខវេ មហាបុរិសស្ស មហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្ក-វត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថា-វរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្ត-រតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្ស-រតនំ មណិរតនំ ឥត្ថីរតនំ គហបតិរតនំ បរិណាយក-រតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសតិ សចេ បន ខោ អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ

លក្ខណកថា

[៥២២] ព្រះពោធិសត្វ ឃើញមហាសុបិន យ៉ាងណា ចក្កវត្តិសត្វ ឃើញមហាសុបិន ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២៣] បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ ប្រកបដោយលក្ខណៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាបុរស ប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ នេះ រមែងមានតែគតិ ២ យ៉ាងប៉ុណ្ណោះ មិនមែនខុសអំពីគតិ ២ យ៉ាងនោះទេ គឺថាបើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ជាធម្មរាជប្រកបដោយធម៌ ជាឥស្សរៈលើផែនដីដែលមានសមុទ្រទាំង ៤ ជាទីបំផុត ឈ្នះអស់សត្រូវទាំងខាងក្នុងខាងក្រៅ ដល់នូវភាពមាំមួនក្នុងជនបទ ប្រកបដោយកែវទាំង ៧ ប្រការ ឯកែវទាំង ៧ ប្រការ នេះ របស់ស្តេចចក្រពត្តិនោះ គឺចក្រកែវ ១ ដំរីកែវ ១ សេះកែវ ១ មណីកែវ ១ ស្ត្រីកែវ ១ គហបតីកែវ ១ បរិនាយកកែវ ១ ទៀតជាគម្រប់ ៧ ព្រះរាជានោះ មានព្រះរាជបុត្រ ច្រើនជាងពាន់ ដែលជាអ្នកក្លៀវក្លា មានសភាពអង់អាច អាចញាំញីនូវសេនានៃស្តេចដទៃបាន ព្រះរាជានោះ មានជ័យជម្នះ នៅគ្រប់គ្រងផែនដីនេះដែលមានសាគរជាទីបំផុត ដោយធម៌ ដោយមិនមានគ្រឿងវាយដំ ដោយមិនមានគ្រឿងកាប់ចាក់ បើចេញចាកផ្ទះចូលទៅកាន់ផ្នួសវិញ នឹងបានជាអរហន្តសម្មាសម្ពុទ្ធ មាន

លោកេ វិវដ្ដតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ លក្ខណសមន្នាគតោ ពោធិសត្តោតិ ។

លក្ខណកថា ។

# និយាមោក្កន្តិកថា

[៤២៤] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៥] ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ សាវកោ ហុត្វា ពុទ្ធោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៦] សាវកោ ហុត្វា ពុទ្ធោ ហោតីតិ ។ អាមន្តា ។ អនុស្សវិយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដំបូលគឺកិលេសបើកហើយ ក្នុងលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ ប្រកបដោយលក្ខណៈ (ដោយពិត) ។

ចប់ លក្ខណកថា ។

# និយាមោក្កន្តិកថា

[៥២៤] ព្រះពោធិសត្វ[១] មាននិយាមៈ[២] យាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២៥] ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ (ព្រះពោធិសត្វ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២៦] (ព្រះពោធិសត្វ) បានជាសាវ័កហើយ ទើបបានត្រាស់ជាព្រះពុទ្ធឬ ។ អើ ។ (បុគ្គលជាព្រះពុទ្ធ) ប្រកបដោយការស្តាប់តាមគេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១ សំដៅយកពោធិសត្វ កាលកើតជាជោតិបាល បានបួសក្នុងសម្នាក់ព្រះកស្សបមានព្រះភាគ ។ ២ ជាឈ្មោះនៃអរិយមគ្គ ។

## និយាមោក្កន្តិកថា

[៤២៧] អនុស្សវិយោតិ[១] ។ អាមន្តា ។ ននុ ភគវា សយម្ភូតិ ។ អាមន្តា ។ ហញ្ចិ ភគវា សយម្ភូ តេន វត រេ វត្តព្វេ អនុស្សវិយោតិ ។

[៤២៨] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ភគវតា ពោធិយា មូលេ តីណេវ សាមញ្ញផលានិ អភិសម្ពុទ្ធានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៩] ននុ ភគវតា ពោធិយា មូលេ ចត្តារិ សាមញ្ញផលានិ អភិសម្ពុទ្ធានីតិ ។ អាមន្តា ។ ហញ្ចិ ភគវតា ពោធិយា មូលេ ចត្តារិ សាមញ្ញផលានិ អភិសម្ពុទ្ធានិ តេន វត រេ វត្តព្វេ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

[៤៣០] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ពោធិសត្តោ ទុក្ករការិកំ អកាសីតិ ។

---

១ អដ្ឋកថាយំ អនុស្សវិកោតិ ទិស្សតិ ។

និយាមោក្កន្តិកថា

[៩២៧] (បុគ្គលជាព្រះពុទ្ធ) ប្រកបដោយការស្តាប់តាមគេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯងឬ ។ អើ ។ បើព្រះមានព្រះភាគ ជាអ្នកត្រាស់ដឹងដោយព្រះអង្គឯង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា (បុគ្គលជាព្រះពុទ្ធ) ប្រកបដោយការស្តាប់តាមគេទេ ។

[៩២៨] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរឬ ។ អើ ។ សាមញ្ញផល ៣ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩២៩] ក្រែងសាមញ្ញផល ៤ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សឬ ។ អើ ។ បើសាមញ្ញផល ៤ គឺព្រះមានព្រះភាគបានត្រាស់ដឹង ទៀបគល់នៃពោធិព្រឹក្សមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេ ។

[៩៣០] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈ ប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ព្រះពោធិសត្វ បានធ្វើទុក្ករកិរិយាដែរឬ ។

អាមន្តា ។ ឥស្សរសម្បន្នោ បុគ្គលោ ឥត្ថត្តំ ការេ-
យ្យ ការយេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣១] ពោធិសត្តោ អបរន្តេ អកាសិ អញ្ញំ សត្ថារំ ឧទ្ទិសីតិ ។ អាមន្តា ។ ឥស្សរសម្បន្នោ បុគ្គលោ អញ្ញំ សត្ថារំ ឧទ្ទិសេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣២] អាយស្មា អានន្ទោ ភគវតោ ចាវចេន ឥក្ខន្តនិយាមោ ចរិតព្រហ្មចរិយោ អាយស្មា អានន្ទោ ភគវតោ សាវកោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ ចាវចេន ឥក្ខន្តនិយាមោ ចរិ-
តព្រហ្មចរិយោ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣៣] ចិត្តោ គហបតិ ហត្ថកោ អាឡវកោ ភគវតោ ចាវចេន ឥក្ខន្តនិយាមោ ចរិតព្រហ្មចរិយោ ចិត្តោ គហបតិ ហត្ថកោ អាឡវកោ ភគវតោ

អើ ។ បុគ្គល បរិបូណ៌ដោយទស្សនៈ គប្បីធ្វើទុក្ករកិរិយាដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣១] ព្រះពោធិសត្វ បានធ្វើអំពើដែលមិនញ៉ាំងបុគ្គលដទៃឲ្យក្តៅក្រហាយ ហើយឧទ្ទិស ចំពោះសាស្តាដទៃដែរឬ ។ អើ ។ បុគ្គលបរិបូណ៌ដោយទស្សនៈ គប្បីឧទ្ទិស ចំពោះសាស្តាដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣២] ព្រះអានន្ទមានអាយុ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ព្រះអានន្ទមានអាយុ ជាសាវ័ក នៃព្រះមានព្រះភាគដែរឬ ។ អើ ។ ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ព្រះពោធិសត្វ ជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣៣] ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ មាននិយាមៈចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ ជាសាវ័ក

សាវកោតិ ។ អាមន្តា ។ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ពោធិសត្តោ កស្សបស្ស ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣៤] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ អាយស្មា អានន្ទោ ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣៥] ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ ចិត្តោ គហបតិ ហត្ថកោ អាឡវកោ ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច ភគវតោ សាវកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

នៃព្រះមានព្រះភាគដែរឬ ។ អើ ។ ព្រះពោធិសត្វ មាននិយាមៈយាង ចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះ ភាគទ្រង់ព្រះនាមកស្សប ព្រះពោធិសត្វជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣៤] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មៈ-ចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាម កស្សប តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ទេឬ ។ អើ ។ ព្រះអានន្ទមានអាយុ មាននិយាមៈយាងចុះហើយ មាន ព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ តែមិនមែនជា សាវ័ក នៃព្រះមានព្រះភាគទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣៥] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មាន ព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះ នាមកស្សប តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាម កស្សបទេឬ ។ អើ ។ ឧបាសកឈ្មោះចិត្តគហបតី និងហត្ថកាឡវកៈ មាននិយាមៈចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃ ព្រះមានព្រះភាគ តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគទេឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៨៣៦] ពោធិសត្តោ កស្សបស្ស ភគវតោ ចាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ ន ច កស្សបស្ស ភគវតោ សាវកោតិ ។ អាមន្តា ។ សាវកោ ជាតឹ វីតិវត្តោ អសាវកោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨៣៧] ន វត្តព្វំ ពោធិសត្តោ កស្សបស្ស ភគវតោ ចាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា កស្សបេ អហំ អានន្ទ ភគវតិ ព្រហ្មចរិយំ អចរឹ អាយតឹ សម្ពោធាយាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពោធិសត្តោ កស្សបស្ស ភគវតោ ចាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

[៨៣៨] ពោធិសត្តោ កស្សបស្ស ភគវតោ ចាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

[៥៣៦] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប តែមិនមែនជាសាវ័ក នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេឬ ។ អើ ។ សាវ័ក ដែលប្រព្រឹត្តកន្លងនូវជាតិហើយ មិនមែនជាសាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣៧] បុគ្គលមិនគួរនិយាយថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ តថាគត បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សប ដើម្បីត្រាស់ដឹងតទៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបដែរ ។

[៥៣៨] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

២០១

និយាមោក្កន្តិកថា

សព្វាភិភូ សព្វវិទូហមស្មិ

សព្វេសុ ធម្មេសុ អនូបលិត្តោ

សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ

សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ

ន មេ អាចរិយោ អត្ថិ សទិសោ មេ ន វិជ្ជតិ

សទេវកស្មឹ លោកស្មឹ នត្ថិ មេ បដិបុគ្គលោ

អហំ ហិ អរហា លោកេ អហំ សត្ថា អនុត្តរោ

ឯកោម្ហិ សម្មាសម្ពុទ្ធោ សីតីភូតោស្មិ និព្វុតោ

ធម្មចក្កំ បវត្តេតុំ គច្ឆាមិ កាសិនំ បុរំ

អន្ធភូតស្មឹ លោកស្មឹ អហញ្ញឹ អមតទុន្ទុភិន្តិ

យថា ខោ ត្វំ អាវុសោ បដិជានាសិ អរហាសិ អនន្តជិនោតិ

និយាមោក្ខន្តិកថា

តថាគត ជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុព្ភូមិកធម៌ទាំងអស់ មិនប្រឡាក់ដោយកិលេសក្នុងតេភូមិកធម៌ទាំងអស់ទេ លះចោលនូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះការអស់ទៅនៃតណ្ហា ដឹងច្បាស់នូវចតុព្ភូមិកធម៌ ដោយខ្លួនឯង (ចាំបាច់) ឧទ្ទិសបុគ្គលណា តថាគត មិនមានអាចារ្យទេ បុគ្គលដទៃស្មើនឹងតថាគតមិនមានឡើយ ក្នុងលោក ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះថា តថាគត ជាអរហន្តក្នុងលោក តថាគត ជាសាស្តាខ្ពស់បំផុត តថាគត ជាសម្មាសម្ពុទ្ធឯក មានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់ហើយ ឥឡូវនេះ តថាគត ទៅកាន់បុរីនៃពួកជនអ្នកកាសី ដើម្បីសម្តែងធម្មចក្រ (ដោយបំណងថា) តថាគត នឹងទូងស្គរគឺអមតនិព្វាន ចំពោះសត្វលោកដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់

(ឧបកាជីវកតបថា) ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នក ថាយ៉ាងណាអ្នក (គួរដើម្បីបាននូវឈ្មោះ) ថាអនន្តជិនៈ យ៉ាងនោះឯង (ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទៀតថា)

មាទិសា វេ ជិនា ហោន្តិ  យេ បត្តា អាសវក្ខយំ
ជិតា មេ បាបកា ធម្មា តស្មាហំ ឧបក ជិនោតិ
អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ
ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្ត-
និយាមោ ចរិតព្រហ្មចរិយោតិ ។

[៥៣៩] ពោធិសត្តោ កស្សបស្ស ភគវតោ
បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។
អាមន្តា ។ ននុ វុត្តំ ភគវតា ឥទំ ទុក្ខំ អរិយ-
សច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ
ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ
វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ តំ ខោ បនិទំ
ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ ។ បេ ។

ជនទាំងឡាយណា បានដល់នូវការអស់ទៅនៃអាសវៈ ជនទាំងឡាយនោះ ឈ្មោះថាជិនៈ (អ្នកឈ្នះកិលេស) ប្រាកដដូចជាតថាគតដែរ តថាគត បានឈ្នះបាបធម៌ទាំងឡាយហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគត បាននូវឈ្មោះថាជិនៈ (អ្នកឈ្នះបាបធម៌)

ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេ ។

[៥៣៩] ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮក្នុងកាលពីមុនមកថា នេះ ជាទុក្ខអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខអរិយសច្ច ដែលបុគ្គលគួរកំណត់ដឹង

២០៣

## និយាមោក្កន្តិកថា

បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេ-
សុ ចក្ខុំ ឧទបាទិ ។ បេ ។ អាលោកោ ឧទបា-
ទិ ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ
។ បេ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយ-
សច្ចំ បហាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ បហីនន្តិ
មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធោ អរិយ-
សច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិ-
រោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ ។ បេ ។
សច្ឆិកតន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិ-
រោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ
។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិ-
បទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ ។ បេ ។

និយាមោក្កន្តិកថា

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ។ បេ ។ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយ ដែលតថាគតមិនធ្លាប់បានឮក្នុងកាលពីមុនមកថា ទុក្ខនោះឯង ដែលតថាគតបានកំណត់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នេះ ជាទុក្ខសមុទយ-អរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខសមុទយអរិយសច្ច ដែលបុគ្គលគួរលះចោល ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខ-សមុទយអរិយសច្ច ដែលតថាគតបានលះចោលហើយ ម្នាលភិក្ខុទាំង-ឡាយ ។ បេ ។ ដល់តថាគតថា នេះ ជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខនិរោធអរិយសច្ច ដែលបុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំង-ឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខនិរោធអរិយសច្ច ដែលតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នេះ ជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា នោះឯង ជាទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច ដែលបុគ្គលគួរចម្រើន ម្នាលភិក្ខុទាំងឡាយ

ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ពោធិសត្តោ កស្សបស្ស ភគវតោ បាវចនេ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោតិ ។

និយាមោក្កន្តិកថា ។

# អបរាបិ សមន្នាគតកថា

[៥៤០] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ចតូហិ ផស្សេហិ ចតូហិ វេទនាហិ ចតូហិ សញ្ញាហិ ចតូហិ ចេតនាហិ ចតូហិ ចិត្តេហិ ចតូហិ សទ្ធាហិ ចតូហិ វីរិយេហិ ចតូហិ សតីហិ ចតូហិ សមាធីហិ ចតូហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនធ្លាប់បានឮក្នុងកាលពីមុនមកថា នោះឯង ជាទុក្ខនិរោធ-គាមិនីបដិបទាអរិយសច្ច ដែលតថាគតបានចម្រើនហើយ ពាក្យដូច្នេះមានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ក្នុងសាសនា នៃព្រះមានព្រះភាគ ទ្រង់ព្រះនាមកស្សបទេ ។

ចប់ និយាមោក្កន្តិកថា ។

# អបរាបិ សមន្នាគតកថា

[៥៤០] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ៤ ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវីរិយៈ ៤ ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អបរាបិ សមន្នាគតកថា

[៥៤១] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផស្សេហិ តីហិ វេទនាហិ ។ បេ ។ តីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥៤២] សកទាគាមិផលសច្ឆិកិរិយាយ បដិ-បន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផស្សេហិ ទ្វីហិ វេទនាហិ ។ បេ ។ ទ្វីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥៤៣] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-លោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតា-បន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អបរាបិ សមន្នាគតកថា

[៥២១] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រកបដោយផល ២ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផស្សៈ ៣ ដោយវេទនា ៣ ។ បេ ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២២] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិ-ផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយផស្សៈ ២ ដោយវេទនា ២ ។ បេ ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២៣] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៤] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ សកទាគាមិផលេន សមន្នាគតោតិ ។ អា-
មន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ
សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៥] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។
អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមី
អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វា-
យី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី-
តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៦] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ
បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អា-
មន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ
ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៧] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។

[៥៤៤] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៤៥] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គល ជាអនាគាមី គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតៈ អកនិដ្ឋគាមី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៤៦] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៤៧] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវ អនាគាមិផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។

អជាតាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ស-
កទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៨] សកទាគាមិផលសច្ឆិកិរិយាយ បដិ-
បន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។
អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ
បុគ្គលោ សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោ-
លោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៩] សោតាបត្តិផលេន សមន្នាគតោ សោ-
តាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិ-
យាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នា-
គតោតិ ។ អាមន្តា ។ ស្វេវ អរហត្តសច្ឆិកិរិយាយ បដិ-
បន្នោ សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៥០] សកទាគាមិផលេន សមន្នាគតោ ស-
កទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហត្តសច្ឆិ-
កិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន
សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហត្តសច្ឆិកិ-
រិយាយ បដិបន្នោ សោ សកទាគាមីតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

សកទាគាមិបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៨] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គលជាសោតាបន្នៈ គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជី ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៩] គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥០] គួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤១] អនាគាមិផលេន សមន្នាគតោ អនាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហត្តសច្ឆិកិរិយាយ បដិបន្នោ សោ អនាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤២] សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៣] សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥៥១] គួរនិយាយថា អនាគាមិបុគ្គល ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៥២] គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៥៣] គួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

២០៩

អបរាបិ សមន្នាគតកថា

[៤៩៤] សោតាបត្តិផលេន សមន្នាគតោ សោ-
តាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ សកបាតាមិ-
ផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិ-
ផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ សកទា-
គាមិផលសច្ឆិកិរិយាយ បដិបន្នោ សោ សោតាបន្នោ-
តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៥] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ សោតាបត្តិផលេន សមន្នាគតោតិ ។ អា-
មន្តា ។ ននុ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ
សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អ-
រហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិ-
ផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហត្តសច្ឆិកិរិ-
យាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន ស-
មន្នាគតោតិ ។

[៤៩៦] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។
អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ វិចិកិច្ឆំ

[៩៥៤] គួរនិយាយថា សោតាបន្នបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៥៥] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសោតាបត្តិផលទេ ។

[៩៥៦] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លង នូវសក្កាយទិដ្ឋិ នូវវិចិកិច្ឆា

សីលព្វតបរាមាសំ អថាយតមនិយំ រាគំ អថាយតម-និយំ ទោសំ អថាយតមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥៥៧] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-លោ សកទាគាមិផលេន សមន្នាគតោតិ ។ អា-មន្តា ។ ននុ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទា-គាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហត្តសច្ឆិ-កិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។

[៥៥៨] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-លោ សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោ-តិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាម-រាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នា-គតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

នូវសីលព្វតបរាមាសៈ នូវរាគៈ ជាដំណើរទៅកាន់អបាយ នូវទោសៈជាដំណើរទៅកាន់អបាយ នូវមោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៥៧] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយសកទាគាមិផលទេ ។

[៥៥៨] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត នូវព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥៩] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។
ជនុ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនា-
គាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហត្ត-
សច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ អនាគាមិផលំ
វីតិវត្តោ នោ វត រេ វត្តព្វេ អរហត្តសច្ឆិកិរិយាយ
បដិបន្នោ បុគ្គលោ អនាគាមិផលេន សមន្នាគតោតិ ។

[៤៦០] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-
លោ អនាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។
អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ
អនាគាមិមគ្គំ វីតិវត្តោ អណុសហគតំ កាមរាគំ អណុ-
សហគតំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៤៦១] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ
បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អា-
មន្តា ។ ជនុ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ
បុគ្គលោ សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។
ហញ្ចិ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ

អបរាបិ សមន្នាគតកថា

[៩៥៩] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយអនាគាមិផលទេ ។

[៩៦០] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិផល ហើយប្រកបដោយអនាគាមិផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រព្រឹត្តកន្លងនូវអនាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រាលស្តើង នូវព្យាបាទដ៏ស្រាលស្តើង ហើយប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៦១] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល

សោតាបត្តិផលំ វីតិវត្តោ ជោ វត រេ វត្តព្វេ អជាតាមិ-ផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិ-ផលេន សមន្នាគតោតិ ។

[៥៦២] អជាតាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ តេន សមន្នា-គតោតិ ។ អាមន្តា ។ អជាតាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយ-ទិដ្ឋឹ ។ បេ ។ អចាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥៦៣] អជាតាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលេន សមន្នាគតោតិ ។ អា-មន្តា ។ ននុ អជាតាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អជាតាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គ-លោ សកទាគាមិផលំ វីតិវត្តោ ជោ វត រេ វត្តព្វេ អជាតាមិផលសច្ចិកិរិយាយ បដិបន្នោ បុគ្គលោ ស-កទាគាមិផលេន សមន្នាគតោតិ ។

ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយសោតាបត្តិផលទេ ។

[៥៦២] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិ-ផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអ-នាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ នូវមោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតា-បត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៦៣] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រកបដោយសកទាគាមិផលទេ ។

២១៣

អបរាបិ សមន្នាគតកថា

[៤៦៤] អជាតាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អជាតាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៥] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ នោ ច វត រេ វត្តព្វេ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៦៦] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ

អបរាបិ សមន្នាគតកថា

[៥៦៤] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយប្រកបដោយសកទាគាមិ-ផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនា-គាមិផល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត នូវព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៦៥] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិ-ផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលទេ ។

[៥៦៦] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគា-មិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិ-ផលនោះឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ

។ បេ ។ អចាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៧] ន វត្តព្វំ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។

[៤៦៨] ន វត្តព្វំ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ

។ បេ ។ នូវមោហៈជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតា-បត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៦៧] បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ ទេឬ ។ អើ ។ ក្រែង បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះ នូវផលទាំង ៣ ហើយ មិនសាបសូន្យ ចាកផលទាំង ៣ នោះទេឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះ នូវផលទាំង ៣ ហើយ មិនសាបសូន្យ ចាកផលទាំង ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផល ៣ មែន ។

[៥៦៨] បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ ទេឬ ។ អើ ។ ក្រែង បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានចំពោះ នូវផលទាំង ២ ហើយ មិនសាបសូន្យ ចាកផលទាំង ២ នោះទេឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិ-ផល បានចំពោះ នូវផលទាំង ២ ហើយ មិនសាបសូន្យ ចាកផលទាំង ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា

អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។

[៤៦៩] ន វត្តព្វំ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន សោតាបត្តិផលំ បដិលទ្ធំ តេន ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន សោតាបត្តិផលំ បដិលទ្ធំ តេន ច អបរិហីនោ តេន វត រេ វត្តព្វេ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៧០] អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ចត្តារោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។

បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផល ២ មែន ។

[៥៦៩] បុគ្គលមិនគួរនិយាយថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលទេឬ ។ អើ ។ ក្រែងបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានចំពោះ នូវសោតាបត្តិផលហើយ មិនសាបសូន្យ ចាកសោតាបត្តិផលនោះទេឬ ។ អើ ។ បើបុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានចំពោះ នូវសោតាបត្តិផលហើយ មិនសាបសូន្យចាកសោតាបត្តិផលនោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលដែរ ។

[៥៧០] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះ នូវផល ៣ ហើយ មិនសាបសូន្យ ចាកផលទាំង ៣ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយផលទាំង ៣ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត បានចំពោះ នូវមគ្គ ៤ ហើយ មិនសាបសូន្យ ចាកមគ្គទាំង ៤ នោះទេឬ ។

អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ចតូហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧១] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន តយោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ តីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧២] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន សោតាបត្តិផលំ បដិលទ្ធំ តេន ច អបរិហីនោតិ ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេន បុគ្គលេន ទ្វេ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។

បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ប្រកបដោយមគ្គទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧១] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានចំពោះ នូវផល ២ ហើយ មិនសាបសូន្យ ចាកផលទាំង ២ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយផលទាំង ២ ឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល បានចំពោះ នូវមគ្គ ៣ ហើយ មិនសាបសូន្យ ចាកមគ្គទាំង ៣ នោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ប្រកបដោយមគ្គទាំង ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧២] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានចំពោះ នូវសោតាបត្តិផលហើយ មិនសាបសូន្យ ចាកសោតាបត្តិផលនោះទេឬ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល បានចំពោះ នូវមគ្គ ២ ហើយ មិនសាបសូន្យ ចាកមគ្គទាំង ២ នោះទេឬ ។

សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទ្វីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អបរាបិ សមន្នាគតកថា ។

# សព្វសញ្ញោជនប្បហានកថា

[៤៧៣] សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។ អាមន្តា ។ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហី-យន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧៤] អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តិ ។ អាមន្តា ។ អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧៥] អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ បជហាតីតិ ។ អាមន្តា ។ ននុ តិណ្ណំ សញ្ញោជនានំ បហានំ សោតាបត្តិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ តិណ្ណំ សញ្ញោជនានំ បហានំ សោតាបត្តិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

*បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ប្រកប ដោយមគ្គទាំង ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ អបរាបិ សមន្នាគតកថា ។

# សព្វសញ្ញោជនប្បហានកថា

[៩៧៣] *ការលះបង់ នូវសញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្តឬ ។ អើ ។ សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៩៧៤] *សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយ អរហត្តមគ្គឬ ។ អើ ។ (ព្រះអរហន្ត) លះបង់ នូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។*

[៩៧៥] *ព្រះអរហន្ត លះបង់ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវសញ្ញោជនៈទាំង ៣ ឈ្មោះថាសោតាបត្តិផលឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការ លះបង់ នូវសញ្ញោជនៈទាំង ៣ ឈ្មោះថាសោតាបត្តិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្តលះបង់ ដោយអរហត្តមគ្គទេ ។*

អរហាត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។ អាមន្តា ។ អរហាត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨៧៦] អរហាត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ បជហាតីតិ ។ អាមន្តា ។ ននុ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហាត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

[៨៧៧] អរហាត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។ អាមន្តា ។ អរហាត្តមគ្គេន អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨៧៨] អរហាត្តមគ្គេន អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ បជហាតីតិ ។ អាមន្តា ។ ននុ កាមរាគព្យាបាទានំ អនវសេសប្បហានំ អនាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។

សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ ព្រះអរហន្ត លះបង់ នូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៧៦] ព្រះអរហន្ត លះបង់ នូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ភាវៈស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ឈ្មោះថាសកទាគាមិផលឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ភាវៈស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ឈ្មោះថាសកទាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គទេ ។

[៩៧៧] សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ (ព្រះអរហន្ត) លះបង់ នូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៧៨] (ព្រះអរហន្ត) លះបង់ នូវកាមរាគៈដ៏ស្រាលស្តើង ព្យាបាទដ៏ស្រាលស្តើង ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវកាមរាគៈនិងព្យាបាទមិនឲ្យមានសេសសល់ ឈ្មោះថាអនាគាមិផលឬ ។ អើ ។

ហញ្ចិ កាមរាគព្យាបាទានំ អនវសេសប្បហានំ អនាគាមិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

[៤៧៩] អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។ អាមន្តា ។ ននុ រូបរាគអរូបរាគមានឧទ្ធច្ចអវិជ្ជាយ អនវសេសប្បហានំ អរហត្តំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ រូបរាគអរូបរាគមានឧទ្ធច្ចអវិជ្ជាយ អនវសេសប្បហានំ អរហត្តំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន សព្វេ សញ្ញោជនា បហីយន្តីតិ ។

[៤៨០] ន វត្តព្វំ សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។ អាមន្តា ។ ននុ អរហតោ សព្វេ សញ្ញោជនា បហីនាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ សព្វេ សញ្ញោជនា បហីនា តេន វត រេ វត្តព្វេ សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។

សព្វសញ្ញោជនប្បហានកថា ។

ចតុត្ថោ វគ្គោ ។

*បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់ នូវកាមរាគៈនិងព្យាបាទ មិនឲ្យមានសេសសល់ ឈ្មោះថាអនាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គទេ ។*

[៩៧៩] *សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានសេសសល់ ឈ្មោះថាអរហត្តឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ការលះបង់រូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជា មិនឲ្យមានសេសសល់ ឈ្មោះថាអរហត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ ដោយអរហត្តមគ្គទេ ។*

[៩៨០] *បុគ្គលមិនគួរនិយាយថា ការលះបង់ នូវសញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្តទេឬ ។ អើ ។ ក្រែងសញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ហើយឬ ។ អើ ។ បើសញ្ញោជនៈទាំងអស់ ព្រះអរហន្ត លះបង់ហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ការលះបង់ នូវសញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្ត ។*

ចប់ សព្វសញ្ញោជនប្បហានកថា ។

ចប់ ចតុត្ថវគ្គ ។

## តស្ស ឧទ្ទានំ

គិហិស្ស អរហា សហ ឧបបត្តិយា អរហា អរហាតោ សព្វេ ធម្មា អនាសវា អរហា ចតូហិ ផលេហិ សមន្នាគតោ ឯវមេវ ឆហិ ឧបេក្ខាហិ ពោជ្ឈិយា ពុទ្ធោ សហ លក្ខណសមន្នាគតោ ពោធិសត្តោ ឱក្កន្តនិយាមោ ចរិតព្រហ្មចរិយោ បដិបន្នកោ ផលេន សមន្នាគតោ សព្វសញ្ញោជនានំ បហានំ អរហត្តន្តិ ។

---

## វិមុត្តកថា

[៤៨១] វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អាមន្តា ។ យំ កិញ្ចិ វិមុត្តិញ្ញាណំ សព្វន្តំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អាមន្តា ។ បច្ចវេក្ខណាញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អាមន្តា ។ គោត្រភុនោ បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

# ឧទ្ទាននៃចតុត្ថវគ្គនោះ គឺ

និយាយអំពី គ្រហស្ថ បានជាព្រះអរហន្ត ១ បានជាព្រះអរហន្តជាមួយគ្នានឹងការកើតឡើង ១ ពួកធម៌ទាំងអស់ មិនមានអាសវៈ របស់ព្រះអរហន្ត ១ ព្រះអរហន្ត ប្រកបដោយផលទាំងបួន ១ ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ យ៉ាង ១ បានជាព្រះពុទ្ធ ដោយពោធិញ្ញាណ ១ ពោធិសត្វ ប្រកបព្រមដោយលក្ខណៈ ១ ព្រះពោធិសត្វ មាននិយាមៈយាងចុះហើយ មានព្រហ្មចរិយៈប្រព្រឹត្តហើយ ១ បុគ្គលអ្នកប្រតិបត្តិប្រកបដោយផល ១ ការលះបង់សញ្ញោជនៈទាំងអស់ ឈ្មោះថាអរហត្ត ១ ។

---

# វិមុត្តកថា

[៥៨១] វិមុត្តិញ្ញាណ ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណណាមួយ វិមុត្តិញ្ញាណទាំងអស់នោះ ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ ឈ្មោះថាវិមុត្តឬ ។ អើ ។ បច្ចវេក្ខណញ្ញាណ ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គលជាគោត្រភូ ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

វិមុត្តកថា

[៤៨២] សោតាបត្តិផលសច្ឆិកិរិយាយ បដិ-បន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ សោតាបន្នស្ស ញាណំ សោតាបត្តិផលំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកាតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ សកទាគាមិស្ស ញាណំ សកទាគាមិ-ផលំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកាតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគាមិផល-សច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ អនាគាមិស្ស ញាណំ អនាគាមិ-ផលំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកាតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តសច្ឆិ-កិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តន្តិ ។ អាមន្តា ។ អរហតោ ញាណំ អរហត្តំ បត្តស្ស បដិលទ្ធស្ស អធិគតស្ស សច្ឆិកាតស្ស ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

វិមុត្តកថា

[៥៨២] វិមុត្តិញ្ញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណរបស់សោតាបន្នបុគ្គល ជាញាណរបស់បុគ្គល ដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណ របស់សកទាគាមិបុគ្គល ជាញាណរបស់បុគ្គលដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវសកទាគា-មិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណ របស់អនាគាមិបុគ្គល ជាញាណរបស់បុគ្គល ដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណរបស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ឈ្មោះថាវិមុត្តឬ ។ អើ ។ ញាណ របស់ព្រះអរហន្ត ជាញាណរបស់បុគ្គលដែលបានដល់ បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ នូវព្រះអរហត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨៣] សោតាបត្តិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អាមន្តា ។ សោតាបត្តិផល-សច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិ-ផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិ-បន្នស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគាមិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អាមន្តា ។ អនាគាមិផល-សច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តផលស-មង្គិស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ អា-មន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៨៤] សោតាបត្តិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញា-ណន្តិ ។ អាមន្តា ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញ្ញាណំ វិមុត្តំ តញ្ច

[៤៨៣] វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយសោតាបត្តិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយសកទាគាមិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គល ដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយអនាគាមិផល ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយអរហត្តផល ឈ្មោះថាវិមុត្តឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ឈ្មោះថាវិមុត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨៤] វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយសោតាបត្តិផល ឈ្មោះថាវិមុត្តឬ វិមុត្តនោះឯង ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថាវិមុត្ត វិមុត្តនោះឯង

## ២២៣

### វិមុត្តកថា

ផលំ បត្តស្ស ញាណន្តិ ។ ឯ ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ អាមន្តា ។ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ ឯ ហេវំ វត្តព្វេ ។ បេ ។ អនាគាមិផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ អាមន្តា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ ឯ ហេវំ វត្តព្វេ ។ បេ ។ អរហត្តផលសមង្គិស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ អាមន្តា ។ អរហត្តសច្ឆិកិរិយាយ បដិបន្នស្ស បុគ្គលស្ស វិមុត្តិញាណំ វិមុត្តំ តញ្ច ផលំ បត្តស្ស ញាណន្តិ ។ ឯ ហេវំ វត្តព្វេ ។ បេ ។

វិមុត្តកថា ។

ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រមព្រៀងដោយ សកទាគាមិផល ឈ្មោះថាវិមុត្ត វិមុត្តនោះឯង ជាញាណ របស់ បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គល ដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ឈ្មោះថាវិមុត្ត វិមុត្តនោះឯង ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អ្នកមិន គួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រម ព្រៀងដោយអនាគាមិផល ឈ្មោះថាវិមុត្ត វិមុត្តនោះឯង ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គល ដែលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ឈ្មោះថាវិមុត្ត វិមុត្តនោះឯង ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិមុត្តិញ្ញាណ របស់បុគ្គលដែលព្រម ព្រៀងដោយអរហត្តផល ឈ្មោះថាវិមុត្ត វិមុត្តនោះឯង ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អើ ។ វិមុត្តិញ្ញាណ របស់បុគ្គល ដេលប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ឈ្មោះថាវិមុត្ត វិមុត្តនោះឯង ជាញាណ របស់បុគ្គលដែលដល់នូវផលឬ ។ អ្នកមិនគួរ ពោលយ៉ាងនេះទេ ។ បេ ។

ចប់ វិមុត្តកថា ។

# អសេក្ខញាណកថា

[៤៨៥] សេក្ខស្ស អសេក្ខំ ញាណំ អត្ថីតិ ។ អាមន្តា ។ សេក្ខោ អសេក្ខំ ធម្មំ ជានាតិ បស្សតិ ទិដ្ឋំ វិទិតំ សច្ឆិកតំ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ សេក្ខោ អសេក្ខំ ធម្មំ ន ជានាតិ ន បស្សតិ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ ន ឧបសម្បជ្ជ វិហរតិ ន កាយេន ផុសិត្វា វិហរតីតិ ។ អាមន្តា ។ ហញ្ចិ សេក្ខោ អសេក្ខំ ធម្មំ ន ជានាតិ ន បស្សតិ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ ន ឧបសម្បជ្ជ វិហរតិ ន កាយេន ផុសិត្វា វិហរតិ នោ ច វត រេ វត្តព្វេ សេក្ខស្ស អសេក្ខំ ញាណំ អត្ថីតិ ។

[៤៨៦] អសេក្ខស្ស អសេក្ខំ ញាណំ អត្ថិ អសេក្ខោ អសេក្ខំ ធម្មំ ជានាតិ បស្សតិ ទិដ្ឋំ វិទិតំ សច្ឆិកតំ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតីតិ ។ អាមន្តា ។ សេក្ខស្ស អសេក្ខំ ញាណំ អត្ថិ

# អសេក្ខញ្ញាណកថា

[៤៨៥] អសេក្ខញ្ញាណ របស់អសេក្ខបុគ្គល មានដែរឬ ។ អើ ។ សេក្ខបុគ្គល ដឹង ឃើញ នូវអសេក្ខធម៌ (បានដល់នូវអសេក្ខធម៌) ដែលខ្លួនឃើញ ដឹង ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្តនៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសេក្ខបុគ្គល មិនដឹង មិនឃើញ នូវអសេក្ខធម៌ (មិនបានដល់នូវអសេក្ខធម៌) ដែលខ្លួនមិនឃើញ មិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនបានពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្តទេឬ ។ អើ ។ បើសេក្ខបុគ្គល មិនដឹង មិនឃើញ នូវអសេក្ខធម៌ (មិនបានដល់នូវអសេក្ខធម៌) ដែលខ្លួនមិនឃើញ មិនដឹង មិនធ្វើឲ្យជាក់ច្បាស់ មិនពាល់ត្រូវ ដោយនាមកាយហើយ សម្រេចសម្រាន្តទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អសេក្ខញ្ញាណ របស់សេក្ខបុគ្គល មានទេ ។

[៧០៨] ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ ឥតោ ចីវរំ ទេន្តិ តំ ចីវរំ តត្ថ បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥតោ បិណ្ឌបាតំ ទេន្តិ ឥតោ សេនាសនំ ទេន្តិ ឥតោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេន្តិ ឥតោ ខាទនីយំ ទេន្តិ ឥតោ ភោជនីយំ ទេន្តិ ឥតោ បានីយំ ទេន្តិ

ទាយកឲ្យទាន កាលបើបដិគ្គាហកៈ ទទួលហើយ ពួកស្តេចយកទៅក្តី ពួកចោរលួចយកទៅក្តី ភ្លើងឆេះក្តី ទឹកបន្សាត់ទៅក្តី ពួកទាយាទៈមិនជាទីស្រឡាញ់យកទៅក្តី បុណ្យ រមែងមានឬ ។ អើ ។ បើទាយកឲ្យទាន កាលបើបដិគ្គាហកៈ ទទួលហើយ ពួកស្តេចយកទៅក្តី ពួកចោរលួចទៅក្តី ភ្លើងឆេះក្តី ទឹកបន្សាត់ទៅក្តី ពួកទាយាទៈមិនជាទីស្រឡាញ់យកទៅក្តី បុណ្យ រមែងមាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរនិយាយថា បុណ្យ សម្រេចដោយការបរិភោគ តែដ៏ចម្រើនទេ ។

ចប់ បរិភោគមយបុញ្ញកថា ។

# ឥតោទិន្នកថា

[៧០៨] ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះ បានដែរឬ ។ អើ ។ ញាតិទាំងឡាយ ឲ្យចីវរ អំពីមនុស្សលោកនេះ ពួកប្រេតបរិភោគចីវរនោះ ក្នុងបេតវិស័យនោះបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកញាតិ ឲ្យបិណ្ឌបាត អំពីមនុស្សលោកនេះ ឲ្យសេនាសនៈ អំពីមនុស្សលោកនេះ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ អំពីមនុស្សលោកនេះ ឲ្យវត្ថុគួរទំពាស៊ី អំពីមនុស្សលោកនេះ ឲ្យវត្ថុគួរបរិភោគ អំពីមនុស្សលោកនេះ ឲ្យទឹកគួរផឹក អំពីមនុស្សលោកនេះ

តំ បានីយំ តត្ថ បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧០៩] ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ អញ្ញោ អញ្ញស្ស ការកោ បរកតំ សុខទុក្ខំ អញ្ញោ ករោតិ អញ្ញោ បដិសំវេទេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១០] ន វត្តព្វំ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ ននុ បេតា អត្តនោ អត្ថាយ ទានំ ទេន្តំ អនុមោទន្តិ ចិត្តំ បសាទេន្តិ បីតឹ ឧប្បាទេន្តិ សោមនស្សំ បដិលភន្តីតិ ។ អាមន្តា ។ ហញ្ចិ បេតា អត្តនោ អត្ថាយ ទានំ ទេន្តំ អនុមោទន្តិ ចិត្តំ បសាទេន្តិ បីតឹ ឧប្បាទេន្តិ សោមនស្សំ បដិលភន្តិ តេន វត រេ វត្តព្វេ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។

ពួកប្រេត បរិភោគទឹកគួរផឹកនោះ ក្នុងបេតវិស័យនោះបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧០៩] ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបានឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើនូវបុគ្គលដទៃ សុខទុក្ខដែលបុគ្គលដទៃធ្វើ បុគ្គលដទៃ ធ្វើ បុគ្គលដទៃ ទទួលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១០] បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះទេឬ ។ អើ ។ ក្រែងពួកប្រេត អនុមោទនា នូវទានដែលញាតិកាលឲ្យ ដើម្បីប្រយោជន៍ខ្លួន ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបីតិឲ្យកើតឡើង បានចំពោះនូវសោមនស្សឬ ។ អើ ។ បើពួកប្រេត អនុមោទនា នូវទាន ដែលញាតិកាលឲ្យ ដើម្បីប្រយោជន៍ខ្លួន ហើយញុំាងចិត្តឲ្យជ្រះថ្លា ញុំាងបីតិឲ្យកើតឡើង បានចំពោះនូវសោមនស្ស ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន ។

[៧១១] ន វត្តព្វំ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ឧណ្ណតេ ឧទកំ វុដ្ឋំ  យថា និន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ  បេតានំ ឧបកប្បតិ
យថា វារិវហា បូរា  បរិបូរេន្តិ សាគរំ
ឯវមេវ ឥតោ ទិន្នំ  បេតានំ ឧបកប្បតិ
ន ហិ តត្ថ កសី អត្ថិ  គោរក្ខេត្ថ ន វិជ្ជតិ
វណិជ្ជា តាទិសី នត្ថិ  ហិរញ្ញេន កយាកយំ
ឥតោ ទិន្នេន យាបេន្តិ  បេតា កាលកតា តហិន្តិ

[៧១១] បុគ្គលមិនគួរនិយាយថា ពួកប្រេត ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះ បានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ទឹកភ្លៀង ដែលមហាមេឃបង្អុរចុះហើយ ក្នុងទីទួល រមែងហូរទៅកាន់ទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីលោកនេះ ក៏រមែងសម្រេចផល ដល់ប្រេតទាំងឡាយ ដូច្នោះឯង ផ្លូវទឹកដ៏ពេញ រមែងញ៉ាំងសាគរគឺសមុទ្រ ឲ្យពេញព្រៀប ដូចម្តេចមិញ ទានដែលបុគ្គលឲ្យហើយ អំពីមនុស្សលោកនេះ ក៏រមែងសម្រេចផល ដល់ប្រេតទាំង-ឡាយ ដូច្នោះឯង ការភ្ជួររាស់ស្រែ ក៏មិនមាន ក្នុងបេតវិស័យនោះ ការរក្សាគោ ក៏មិនមាន ក្នុងបេតវិស័យនោះ ការជួញប្រែជាហេតុបាននូវសម្បត្តិ ប្រាកដដូច្នោះ ក៏មិនមាន ការលក់ទិញ ផ្លាស់ប្តូរដោយប្រាក់ ក៏មិនមាន ពួកប្រេតកាលធ្វើកាលកិរិយាទៅកើត ក្នុងបេតវិស័យនោះ រមែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន

ឥតោទិន្នកថា

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។

[៧១២] ន វត្តព្វំ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមានិ ភិក្ខវេ ឋានានិ សម្បស្សន្តា មាតាបិតរោ បុត្តំ ឥច្ឆន្តិ កុលេ ជាយមានំ ។ កតមានិ បញ្ច ។ ភតោ វា នោ ភរិស្សតិ កិច្ចំ វា នោ ករិស្សតិ កុលវំសោ ចិរំ ឋស្សតិ ទាយជ្ជំ បដិបជ្ជតិ អថ វា បន បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សតីតិ ឥមានិ ខោ ភិក្ខវេ បញ្ច ឋានានិ សម្បស្សន្តា មាតាបិតរោ បុត្តំ ឥច្ឆន្តិ កុលេ ជាយមានន្តិ

បញ្ច ឋានានិ សម្បស្សំ បុត្តំ ឥច្ឆន្តិ បណ្ឌិតា
ភតោ វា នោ ភរិស្សតិ កិច្ចំ វា នោ ករិស្សតិ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកប្រេត ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះបាន ។

[៧១២] បុគ្គលមិនគួរនិយាយថា ពួកប្រេត ញុំាំងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មាតានិងបិតា កាលឃើញច្បាស់ នូវស្ថាន ៥ យ៉ាងនេះ ទើបប្រាថ្នាបុត្រ ដែលកើតក្នុងត្រកូល ។ ស្ថានទាំង ៥ យ៉ាង តើដូចម្តេច ។ គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងធ្វើកិច្ចរបស់យើង ១ វង្សត្រកូលនឹងឋិតនៅអស់កាលយូរ ១ បុត្រនឹងទទួលគ្រប់គ្រងមត៌ក ១ មួយទៀត បុត្រនឹងឧទ្ទិសបញ្ជូនទក្ខិណាទានដល់យើង ដែលធ្វើកាលកិរិយាទៅកើត ក្នុងបរលោកនាយ ១ ម្នាលភិក្ខុទាំងឡាយ មាតានិងបិតា កាលឃើញច្បាស់ នូវស្ថានទាំង ៥ យ៉ាងនេះឯង ទើបប្រាថ្នាបុត្រដែលកើត ក្នុងត្រកូល

បណ្ឌិតទាំងឡាយ កាលបើឃើញច្បាស់ នូវស្ថាន ទាំង ៥
យ៉ាងហើយ ទើបប្រាថ្នាបុត្រ (ដោយគិតថា) បុត្រដែលយើង
ចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ ១ នឹងធ្វើកិច្ចរបស់យើង ១

កុលវំសោ ចិរំ តិដ្ឋេ  ទាយជ្ជំ បដិបជ្ជតិ
អថ វា បន បេតានំ  ទក្ខិណំ អនុប្បទស្សតិ
ឋានានេតានិ សម្បស្សំ  បុត្តំ ឥច្ឆន្តិ បណ្ឌិតា
តស្មា សន្តោ សប្បុរិសា  កតញ្ញូ កតវេទិនោ
ភរន្តិ មាតាបិតរោ  បុព្វេ កតមនុស្សរំ
ករោន្តិ តេសំ កិច្ចានិ  យថា តំ បុព្វការិនំ
ឱវាទការី ភដបោសី  កុលវំសំ អហាបយំ

សទ្ធោ សីលេន សម្បន្នោ បុត្តោ ហោតិ បសំសិយោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឥតោ ទិន្នេន តត្ថ យាបេន្តីតិ ។

ឥតោ ទិន្នកថា ។

*វង្សត្រកូលគប្បីឋិតនៅអស់កាលយូរ ១ បុត្រនឹងទទួលគ្រប់គ្រងមត៌ក ១ មួយទៀត បុត្រនឹងឧទ្ទិសបញ្ជូនទក្ខិណាទានដល់យើង ដែលធ្វើកាលកិរិយាទៅកើត ក្នុងបរលោក ១ បណ្ឌិតទាំងឡាយ កាលបើឃើញច្បាស់ នូវស្ថានទាំង ៥ យ៉ាងនេះឯង ទើបប្រាថ្នាបុត្រ ព្រោះហេតុនោះ សប្បុរសទាំងឡាយ មានចិត្តរម្ងាប់ហើយ អ្នកដឹងនូវឧបការគុណដែលគេធ្វើហើយប្រាកដ កាលរឭកឃើញ នូវឧបការ-គុណដែលមាតាបិតាធ្វើហើយ ក្នុងកាលមុន រមែងចិញ្ចឹមមាតាបិតា ធ្វើកិច្ចទាំងឡាយ ដល់មាតានិងបិតាទាំងនោះ ដែលជាបុព្វការី ដោយពិត បុត្រជាអ្នកធ្វើតាមឱវាទ អ្នកចិញ្ចឹមមាតាបិតា ដែលចិញ្ចឹមខ្លួន ញុំាងវង្សត្រកូល មិនឲ្យវិនាស ជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល អ្នកប្រាជ្ញរមែងសរសើរ ។*

*ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកប្រេតញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបេតវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីមនុស្សលោកនេះ ។*

ចប់ ឥតោទិន្នកថា ។

# បឋវី កម្មវិបាកោតិកថា

[៧១៣] បឋវី កម្មវិចាកោតិ ។ អាមន្តា ។ សុខវេទនិយា ទុក្ខវេទនិយា អទុក្ខមសុខវេទនិយា សុខាយ វេទនាយ សម្បយុត្តា ទុក្ខាយ វេទនាយ សម្បយុត្តា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ផស្សេន សម្បយុត្តា វេទនាយ សម្បយុត្តា សញ្ញាយ សម្បយុត្តា ចេតនាយ សម្បយុត្តា ចិត្តេន សម្បយុត្តា សារម្មណា អត្ថិ តាយ អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយា ន ទុក្ខវេទនិយា ន អទុក្ខមសុខវេទនិយា ន សុខាយ វេទនាយ សម្បយុត្តា ន ទុក្ខាយ វេទនាយ សម្បយុត្តា ន អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ន ផស្សេន សម្បយុត្តា ន វេទនាយ សម្បយុត្តា ន សញ្ញាយ សម្បយុត្តា ន ចេតនាយ សម្បយុត្តា ន ចិត្តេន សម្បយុត្តា អនារម្មណា នត្ថិ តាយ អាវដ្ដនា អាភោគោ សមន្នាហារោ មនសិការោ

# បបរីកម្មវិបាកោតិកថា

[៧១៣] ប្រឹថពី ជាវិបាក (ផល) នៃកម្មឬ ។ អើ ។ ប្រឹថពី គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួដល់ការរងអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតិ ប្រកបដោយអារម្មណ៍ ការទឹកនា ការអើពើ ការពិចារណា ការធ្វើ ទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក (នូវសេចក្ដីប្រាថ្នា) នៃប្រឹថពីនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងប្រឹថពី មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ មិនគួរដល់ ការរងអារម្មណ៍ មិនជាទុក្ខ មិនជាសុខ មិនប្រកបដោយសុខវេទនា មិនប្រកបដោយទុក្ខវេទនា មិនប្រកបដោយអទុក្ខមសុខវេទនា មិន ប្រកបដោយផស្សៈ មិនប្រកបដោយវេទនា មិនប្រកបដោយសញ្ញា មិនប្រកបដោយចេតនា មិនប្រកបដោយចិត្ត ជាធម្មជាតិមិនមាន អារម្មណ៍ ការទឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត

ចេតនា បត្តនា បណិធីតិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយា ន ទុក្ខវេទនិយា ។ បេ ។ អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធិ នោ វត វេ វត្តព្វេ បបរី កម្មវិចាកោតិ ។

[៧១៤] ផស្សោ កម្មវិចាកោ ផស្សោ សុខវេទនិយោ ទុក្ខវេទនិយោ អទុក្ខមសុខវេទនិយោ សុខាយ វេទនាយ សម្បយុត្តោ ទុក្ខាយ ។ បេ ។ អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ផស្សេន សម្បយុត្តោ វេទនាយ សម្បយុត្តោ សញ្ញាយ សម្បយុត្តោ ចេតនាយ សម្បយុត្តោ ចិត្តេន សម្បយុត្តោ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ បបរី កម្មវិចាកោ បបរី សុខវេទនិយា ទុក្ខវេទនិយា អទុក្ខមសុខវេទនិយា សុខាយ វេទនាយ សម្បយុត្តា ទុក្ខាយ វេទនាយ សម្បយុត្តា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ផស្សេន សម្បយុត្តា វេទនាយ សម្បយុត្តា សញ្ញាយ

ការគិត ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រីថពីនោះ មិនមានទេឬ ។ អើ ។ បើប្រីថពី មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹក ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រីថពីនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ប្រីថពី ជាវិបាកនៃកម្មទេ ។

[៧១៤] ផស្សៈ ជាវិបាកនៃកម្ម ផស្សៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអារម្មណ៍ មិនជាទុក្ខមិនជាសុខ ប្រកបដោយសុខវេទនា ដោយទុក្ខវេទនា ។ បេ ។ ប្រកបដោយអទុក្ខមសុខ-វេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាសភាវៈប្រកបដោយអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃផស្សៈនោះ មានដែរឬ ។ អើ ។ ប្រីថពី ជាវិបាកនៃកម្ម ប្រីថពី គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអារម្មណ៍ មិនជាទុក្ខមិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខម-សុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា

សម្បយុត្តា ចេតនាយ សម្បយុត្តា ចិត្តេន សម្បយុត្តា សារម្មណា អត្ថិ តាយ អាវជ្ជនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១៥] បឋវី កម្មវិបាកោ បឋវី ន សុខវេទនិយា ន ទុក្ខវេទនិយា ។ បេ ។ អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ផស្សោ កម្មវិបាកោ ផស្សោ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១៦] បឋវី កម្មវិបាកោតិ ។ អាមន្តា ។ បឋវី បត្តហានិក្តហូបកា ធេននភេនន្ទូបតាតិ ។ អាមន្តា ។ កម្មវិបាកោ បត្តហានិក្តហូបកោ ធេននភេនន្ទូបកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១៧] លព្ភា បឋវី កេតុំ វិកេតុំ អាឋបេតុំ ឱចិនិតុំ វិចិនិតុន្តិ ។ អាមន្តា ។ លព្ភា កម្មវិបាកោ

ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតិប្រកបដោយអារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១៥] ប្រឹថពី ជាវិបាកនៃកម្ម ប្រឹថពី មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាធម្មជាតិមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃប្រឹថពីនោះ មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាកនៃកម្ម ផស្សៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាសភាវៈមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១៦] ប្រឹថពី ជាវិបាកនៃកម្មឬ ។ អើ ។ ប្រឹថពី គួរដល់ការលើកឡើងនិងការដាក់ចុះ គួរដល់ការដាច់បង់និងការបែកធ្លាយដែរឬ ។ អើ ។ វិបាកនៃកម្ម គួរដល់ការលើកឡើងនិងការដាក់ចុះ គួរដល់ការដាច់បង់និងការបែកធ្លាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១៧] ប្រឹថពី បុគ្គលគប្បីបាន ដើម្បីទិញ ដើម្បីលក់ ដើម្បីតម្កល់ទុក ដើម្បីសន្សំទុក ដើម្បីជ្រើសរើសដែរឬ ។ អើ ។ វិបាកនៃកម្ម

កោតុំ វិកោតុំ អាបេតុំ ឱចិនិតុំ វិចិនិតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១៨] បថវី បរេសំ សាធារណាតិ ។ អាមន្តា ។ កម្មវិបាកោ បរេសំ សាធារណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១៩] កម្មវិបាកោ បរេសំ សាធារណោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អសាធារណមញ្ញេសំ អចោរហរណោ និធិ
កយិរាថ មច្ចោ បុញ្ញានិ ស វេ សុចរិតំ ចរេតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ កម្មវិបាកោ បរេសំ សាធារណោតិ ។

[៧២០] បថវី កម្មវិបាកោតិ ។ អាមន្តា ។ បឋមំ បថវី សណ្ឋាតិ បច្ឆា សត្តា ឧប្បជ្ជន្តីតិ ។ អាមន្តា ។ បឋមំ វិបាកោ ឧប្បជ្ជតិ បច្ឆា វិបាកប្បដិលាភាយ កម្មំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២១] បថវី សព្វសត្តានំ កម្មវិបាកោតិ ។ អាមន្តា ។ សព្វេ សត្តា បថវី បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ

បុគ្គលគប្បីបាន ដើម្បីទិញ ដើម្បីលក់ ដើម្បីតម្កល់ទុក ដើម្បីសន្សំទុក ដើម្បីជ្រើសរើសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១៨] ប្រឹថពី ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អើ ។ វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១៩] វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កំណប់ទ្រព្យគឺបុណ្យ មិនជាសាធារណៈ ដល់ពួកសត្វដទៃ
ទេ ចោរលួចយកមិនបានទេ សត្វនោះ គប្បីធ្វើបុណ្យទាំង-
ឡាយ គប្បីប្រព្រឹត្តធម៌នោះ ឲ្យសុចរិតដោយពិត

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា វិបាកនៃកម្ម ជាសាធារណៈ ដល់ពួកសត្វដទៃទេ ។

[៧២០] ប្រឹថពី ជាវិបាកនៃកម្មឬ ។ អើ ។ ប្រឹថពី តាំងនៅមុន ហើយទើបសត្វទាំងឡាយ កើតឡើងជាខាងក្រោយឬ ។ អើ ។ វិបាក កើតឡើងមុន ទើបសត្វទាំងឡាយ ធ្វើកម្ម ដើម្បីបាននូវវិបាកក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២១] ប្រឹថពី ជាវិបាកនៃកម្ម របស់សត្វទាំងអស់ឬ ។ អើ ។ សត្វទាំងអស់ បរិភោគប្រឹថពីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

## បឋវី កម្មវិបាកោតិកថា

។ បេ ។ សព្វេ សត្តា បឋវឹ បរិភុញ្ជន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ បឋវឹ បរិភុញ្ជិត្វា បរិនិព្វាយន្តីតិ ។ អាមន្តា ។ អត្ថិ កេចិ កម្មវិបាកំ អខេបេត្វា បរិនិព្វាយន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២២] បឋវី ចក្កវត្តិសត្តស្ស កម្មវិបាកោតិ ។ អាមន្តា ។ អញ្ញេ សត្តា បឋវឹ បរិភុញ្ជន្តីតិ ។ អាមន្តា ។ ចក្កវត្តិសត្តស្ស កម្មវិបាកំ អញ្ញេ សត្តា បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្កវត្តិសត្តស្ស កម្មវិបាកំ អញ្ញេ សត្តា បរិភុញ្ជន្តីតិ ។ អាមន្តា ។ ចក្កវត្តិសត្តស្ស ផស្សំ វេទនំ សញ្ញំ ចេតនំ ចិត្តំ សទ្ធំ វីរិយំ សតឹ សមាធឹ បញ្ញំ អញ្ញេ សត្តា បរិភុញ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២៣] ន វត្តព្វំ បឋវី កម្មវិបាកោតិ ។ អាមន្តា ។ ននុ អត្ថិ ឥស្សរិយសំវត្តនិយំ កម្មំ អធិបច្ចសំវត្តនិយំ កម្មន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ ឥស្សរិយសំវត្តនិយំ កម្មំ អធិបច្ចសំវត្តនិយំ កម្មំ តេន វត រេ វត្តព្វេ បឋវី កម្មវិបាកោតិ ។

បឋវី កម្មវិបាកោតិកថា ។

។ បេ ។ សត្វទាំងអស់ បរិភោគប្រឹថពីឬ ។ អើ ។ សត្វពួកខ្លះ បរិភោគប្រឹថពី ហើយរលត់ទៅ មានដែរឬ ។ អើ ។ សត្វពួកខ្លះ ញុំាងវិបាកនៃកម្មមិនឲ្យអស់ទៅ ហើយរលត់ទៅ មានដែឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២២] ប្រឹថពី ជាវិបាកនៃកម្ម របស់សត្វជាចក្រពត្តិឬ ។ អើ ។ ពួកសត្វដទៃ បរិភោគប្រឹថពីឬ ។ អើ ។ ពួកសត្វដទៃ បរិភោគវិបាកនៃកម្ម របស់សត្វជាចក្រពត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វដទៃ បរិភោគវិបាកនៃកម្ម របស់សត្វជាចក្រ-ពត្តិឬ ។ អើ ។ ពួកសត្វដទៃ បរិភោគផស្សៈ វេទនា សញ្ញា ចេតនា ចិត្ត សទ្ធា វីរិយៈ សតិ សមាធិ បញ្ញា របស់សត្វជាចក្រពត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២៣] បុគ្គលមិនគួរនិយាយថា ប្រឹថពី ជាវិបាកនៃកម្មទេឬ ។ អើ ។ ក្រែងកម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាឥស្សរៈ កម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាអធិបតី មានដែរឬ ។ អើ ។ បើកម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាឥស្សរៈ កម្មដែលគួរដល់ការប្រព្រឹត្តទៅ ដើម្បីភាវៈនៃខ្លួនជាអធិបតី រមែងមាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ប្រឹថពី ជាវិបាកនៃកម្ម ។

ចប់ បបរិកម្មវិបាកោតិកថា ។

# ជរាមរណំ វិបាកោតិកថា

[៧២៤] ជរាមរណំ វិបាកោតិ ។ អាមន្តា ។ សុខវេទនិយំ ទុក្ខវេទនិយំ អទុក្ខមសុខវេទនិយំ សុខាយ វេទនាយ សម្បយុត្តំ ទុក្ខាយ វេទនាយ សម្បយុត្តំ អទុក្ខមសុខាយ វេទនាយ សម្បយុត្តំ ផស្សេន សម្បយុត្តំ វេទនាយ សម្បយុត្តំ សញ្ញាយ សម្បយុត្តំ ចេតនាយ សម្បយុត្តំ ចិត្តេន សម្បយុត្តំ សារម្មណំ អត្ថិ តស្ស អាវជ្ជនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ ជរាមរណំ វិបាកោតិ ។

# ជរាមរណវិបាកោតិកថា

[៧២៤] ជរានិងមរណៈ ជាវិបាកឬ ។ អើ ។ ជរានិងមរណៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ គួរដល់ការរងអារម្មណ៍ មិនជាទុក្ខ មិនជាសុខ ប្រកបដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយ អទុក្ខមសុខវេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយ សញ្ញា ប្រកបដោយចេតនា ប្រកបដោយចិត្ត ជាធម្មជាតប្រកបដោយ អារម្មណ៍ ការនឹកនា ការអើពើ ការពិចារណា ការផ្ចើទុកក្នុងចិត្ត ការ គិត ការប្រាថ្នា ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃជរានិងមរណៈ នោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងជរានិង មរណៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាធម្ម-ជាតមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តី ប្រាថ្នា) នៃជរានិងមរណៈនោះ មិនមានទេឬ ។ អើ ។ បើជរានិង មរណៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាធម្ម-ជាតមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តី ប្រាថ្នា) នៃជរានិងមរណៈនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នក មិនគួរពោលថា ជរានិងមរណៈ ជាវិបាកទេ ។

## ជរាមរណំ វិបាកោតិកថា

[៧២៥] ផស្សោ វិបាកោ ផស្សោ សុខវេទនិយោ ទុក្ខវេទនិយោ ។ បេ ។ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ជរាមរណំ វិបាកោ ជរាមរណំ សុខវេទនិយំ ទុក្ខវេទនិយំ ។ បេ ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២៦] ជរាមរណំ វិបាកោ ជរាមរណំ ន សុខវេទនិយំ ន ទុក្ខវេទនិយំ ។ បេ ។ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ផស្សោ វិបាកោ ផស្សោ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២៧] អកុសលានំ ធម្មានំ ជរាមរណំ អកុសលានំ ធម្មានំ វិបាកោតិ ។ អាមន្តា ។ កុសលានំ ធម្មានំ ជរាមរណំ កុសលានំ ធម្មានំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២៥] ផស្សៈ ជាវិបាក ផស្សៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។ បេ ។ ជាសភាវៈប្រកបដោយអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃផស្សៈនោះ មានដែរឬ ។ អើ ។ ជរានិងមរណៈ ជាវិបាក ជរានិងមរណៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។ បេ ។ ជាធម្មជាតប្រកបដោយអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) ជរានិងមរណៈនោះមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២៦] ជរានិងមរណៈ ជាវិបាក ជរានិងមរណៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាធម្មជាតមិនមានអារម្មណ៍ ការនឹកនា ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃជរានិងមរណៈនោះ មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាក ផស្សៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ ជាសភាវៈមិនមានអារម្មណ៍ ការនឹក ។ បេ ។ ការតាំងទុក (នូវសេចក្តីប្រាថ្នា) នៃផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២៧] ជរានិងមរណៈ នៃពួកកុសលធម៌ ជាវិបាកនៃអកុសលធម៌ឬ ។ អើ ។ ជរានិងមរណៈ នៃពួកកុសលធម៌ ជាវិបាកនៃពួកកុសលធម៌ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២៨] កុសលានំ ធម្មានំ ផាសរណំ ន វត្តព្វំ កុសលានំ ធម្មានំ វិចាកោតិ ។ អាមន្តា ។ អកុសលានំ ធម្មានំ ផាសរណំ ន វត្តព្វំ អកុសលានំ ធម្មានំ វិចាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២៩] កុសលានំ ធម្មានំ ផាសរណំ អកុសលានំ ធម្មានំ វិចាកោតិ ។ អាមន្តា ។ អកុសលានំ ធម្មានំ ផាសរណំ កុសលានំ ធម្មានំ វិចាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៣០] អកុសលានំ ធម្មានំ ផាសរណំ ន វត្តព្វំ កុសលានំ ធម្មានំ វិចាកោតិ ។ អាមន្តា ។ កុសលានំ ធម្មានំ ផាសរណំ ន វត្តព្វំ អកុសលានំ ធម្មានំ វិចាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៣១] កុសលានញ្ច អកុសលានញ្ច ធម្មានំ ផាសរណំ អកុសលានំ ធម្មានំ វិចាកោតិ ។ អា-មន្តា ។ កុសលានញ្ច អកុសលានញ្ច ធម្មានំ ផាស-រណំ កុសលានំ ធម្មានំ វិចាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧២៨] ជវនិង្គមរណៈ នៃពួកកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកកុសលធម៌ទេឬ ។ អើ ។ ជវនិង្គមរណៈ នៃពួក អកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧២៩] ជវនិង្គមរណៈ នៃពួកកុសលធម៌ ជាវិបាក នៃពួក អកុសលធម៌ឬ ។ អើ ។ ជវនិង្គមរណៈ នៃពួកអកុសលធម៌ ជា វិបាក នៃពួកកុសលធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣០] ជវនិង្គមរណៈ នៃពួកអកុសលធម៌ មិនគួរនិយាយ ថា ជាវិបាក នៃពួកកុសលធម៌ទេឬ ។ អើ ។ ជវនិង្គមរណៈ នៃ ពួកកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣១] ជវនិង្គមរណៈ នៃពួកកុសលធម៌ និងពួកអកុសល-ធម៌ ជាវិបាក នៃពួកអកុសលធម៌ឬ ។ អើ ។ ជវនិង្គមរណៈ នៃ ពួកកុសលធម៌ និងពួកអកុសលធម៌ ជាវិបាក នៃពួកកុសលធម៌ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣២] កុសលាកុសលញ្ច អកុសលញ្ច ជម្មាជំ ជរាមរណំ ន វត្តព្វំ កុសលាជំ ជម្មាជំ វិបាកោតិ ។ អាមន្តា ។ កុសលញ្ច អកុសលញ្ច ជម្មាជំ ជរាមរណំ ន វត្តព្វំ អកុសលាជំ ជម្មាជំ វិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៣៣] ន វត្តព្វំ ជរាមរណំ វិបាកោតិ ។ អាមន្តា ។ ននុ អត្ថិ ទុព្វណ្ណសំវត្តនិយំ កម្មំ អប្បាយុកសំវត្តនិយំ កម្មន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ ទុព្វណ្ណសំវត្តនិយំ កម្មំ អប្បាយុកសំវត្តនិយំ កម្មំ តេន វត រេ វត្តព្វេ ជរាមរណំ វិបាកោតិ ។

ជរាមរណំ វិបាកោតិកថា ។

# អរិយធម្មវិបាកកថា

[៧៣៤] នត្ថិ អរិយធម្មវិបាកោតិ ។ អាមន្តា ។ ននុ មហប្ផលំ សាមញ្ញំ មហប្ផលំ ព្រហ្មញ្ញន្តិ ។ អាមន្តា ។ ហញ្ចិ មហប្ផលំ សាមញ្ញំ មហប្ផលំ ព្រហ្មញ្ញំ នោ វត រេ វត្តព្វេ នត្ថិ អរិយធម្មវិបាកោតិ ។

[៧៣៥] នត្ថិ អរិយធម្មវិបាកោតិ ។ អាមន្តា ។

[៧៣២] ជរានិងមរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកកុសលធម៌ទេឬ ។ អើ ។ ជរានិង មរណៈ នៃពួកកុសលធម៌ និងពួកអកុសលធម៌ មិនគួរនិយាយថា ជាវិបាក នៃពួកអកុសលធម៌ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣៣] បុគ្គលមិនគួរនិយាយថា ជរានិងមរណៈ ជាវិបាក ទេឬ ។ អើ ។ ក្រែងកម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីពណ៌អាក្រក់ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីអាយុខ្លី មានដែរឬ ។ អើ ។ បើ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីពណ៌អាក្រក់ កម្មគួរដល់ការប្រព្រឹត្តទៅ ដើម្បីអាយុខ្លី មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោល ថា ជរានិងមរណៈ ជាវិបាក ។

ចប់ ជរាមរណវិបាកោតិកថា ។

# អរិយធម្មវិបាកកថា

[៧៣៤] វិបាកនៃអរិយធម៌ (មគ្គ) មិនមានទេឬ ។ អើ ។ ក្រែង សាមញ្ញៈ (មគ្គ) ជាផលដ៏ប្រសើរ ព្រហ្មញ្ញៈ ជាផលដ៏ប្រសើរ ឬ ។ អើ ។ បើសាមញ្ញៈ ជាផលដ៏ប្រសើរ ព្រហ្មញ្ញៈ ជាផលដ៏ ប្រសើរ (រមែងមាន) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃ អរិយធម៌ មិនមានទេ ។

[៧៣៥] វិបាកនៃអរិយធម៌ មិនមានទេឬ ។ អើ ។

ននុ អត្ថិ សោតាបត្តិផលន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ សោតាបត្តិផលំ តេន វត រេ វត្តព្វេ នត្ថិ អរិយធម្មវិចារកោតិ ។ ននុ អត្ថិ សកទាគាមិផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អរហត្តផលំ តេន វត រេ វត្តព្វេ នត្ថិ អរិយធម្មវិចារកោតិ ។

[៧៣៦] សោតាបត្តិផលំ ន វិចារកោតិ ។ អាមន្តា ។ ទានផលំ ន វិចារកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតាបត្តិផលំ ន វិចារកោតិ ។ អាមន្តា ។ សីលផលំ ។ បេ ។ ភាវនាផលំ ន វិចា-កោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលំ ន វិចារកោតិ ។ អាមន្តា ។ ទានផលំ ន វិចារកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តផលំ ន វិចារកោតិ ។ អាមន្តា ។ សីលផលំ ។ បេ ។ ភាវនាផលំ ន វិចា-កោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៣៧] ទានផលំ វិចារកោតិ ។ អាមន្តា ។ សោតាបត្តិផលំ វិចារកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ក្រែងសោតាបត្តិផល មានឬ ។ អើ ។ បើសោតាបត្តិផល មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។ ក្រែងសកទាគាមិផល ។ បេ ។ អនាគាមិផល ។ បេ ។ អរហត្តផល មានឬ ។ អើ ។ បើ អរហត្តផល មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វិបាកនៃអរិយធម៌ មិនមានទេ ។

[៧៣៦] សោតាបត្តិផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃទាន មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតាបត្តិផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃសីល ។ បេ ។ ផលនៃភាវនា មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សកទាគាមិផល ។ បេ ។ អនាគាមិផល ។ បេ ។ អរហត្តផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃទាន មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរហត្តផល មិនមែនជាវិបាកទេឬ ។ អើ ។ ផលនៃសីល ។ បេ ។ ផលនៃភាវនា មិនមែនជាវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣៧] ផលនៃទាន ជាវិបាកឬ ។ អើ ។ សោតាបត្តិផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ធានផលំ វិចារោតិ ។ អាមន្តា ។ សកទាគាមិ-
ផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលំ
វិចារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សីលផលំ
។ បេ ។ ភាវនាផលំ វិចារោតិ ។ អាមន្តា ។
សោតាបត្តិផលំ វិចារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
ភាវនាផលំ វិចារោតិ ។ អាមន្តា ។ សកទាគាមិ-
ផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលំ
វិចារោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៣៨] កាមាវចរំ កុសលំ សវិចារកន្តិ ។
អាមន្តា ។ លោកុត្តរំ កុសលំ សវិចារកន្តិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ រូបាវចរំ កុសលំ ។ បេ ។
អរូបាវចរំ កុសលំ សវិចារកន្តិ ។ អាមន្តា ។ លោ-
កុត្តរំ កុសលំ សវិចារកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៣៩] លោកុត្តរំ កុសលំ អវិចារកន្តិ ។
អាមន្តា ។ កាមាវចរំ កុសលំ អវិចារកន្តិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ លោកុត្តរំ កុសលំ អវិចា-
រកន្តិ ។ អាមន្តា ។ រូបាវចរំ ។ បេ ។ អរូបាវចរំ
កុសលំ អវិចារកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ផលនៃទាន ជាវិបាកឬ ។ អើ ។ សកទាគាមិផល ។ បេ ។ អនាគាមិ-ផល ។ បេ ។ អរហត្តផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ផលនៃសីល ។ បេ ។ ផលនៃភាវនា ជាវិបាកឬ ។ អើ ។ សោតាបត្តិផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ផលនៃភាវនា ជាវិបាកឬ ។ អើ ។ សកទាគាមិផល ។ បេ ។ អនាគា-មិផល ។ បេ ។ អរហត្តផល ជាវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣៨] កាមាវចរកុសល ប្រកបដោយវិបាកឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូបាវចរកុសល ។ បេ ។ អរូបាវចរកុសល ប្រកបដោយវិបាកឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៣៩] លោកុត្តរកុសល មិនមានវិបាកទេឬ ។ អើ ។ កាមាវចរកុសល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ លោកុត្តរកុសល មិនមានវិបាកទេឬ ។ អើ ។ រូបាវចរៈ ។ បេ ។ អរូបាវចរកុសល មិនមានវិបាកទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤០] កាមាវចរំ កុសលំ សវិបាកំ អាចយគាមីតិ ។ អាមន្តា ។ លោកុត្តរំ កុសលំ សវិបាកំ អាចយគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបាវចរំ ។ បេ ។ អរូបាវចរំ កុសលំ សវិបាកំ អាចយគាមីតិ ។ អាមន្តា ។ លោកុត្តរំ កុសលំ សវិបាកំ អាចយគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៤១] លោកុត្តរំ កុសលំ សវិបាកំ អបចយគាមីតិ ។ អាមន្តា ។ កាមាវចរំ កុសលំ សវិបាកំ អបចយគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លោកុត្តរំ កុសលំ សវិបាកំ អបចយគាមីតិ ។ អាមន្តា ។ រូបាវចរំ ។ បេ ។ អរូបាវចរំ កុសលំ សវិបាកំ អបចយគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អរិយធម្មវិបាកកថា ។

# វិបាកោ វិបាកធម្មធម្មោតិកថា

[៧៤២] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។

[៧៤០] *កាមាវចរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូបាវចរៈ ។ បេ ។ អរូបាវចរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អើ ។ លោកុត្តរកុសល ប្រកបដោយវិបាក ដល់នូវការសន្សំកពូនឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៧៤១] *លោកុត្តរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អើ ។ កាមាវចរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ លោកុត្តរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អើ ។ រូបាវចរៈ ។ បេ ។ អរូបាវចរកុសល ប្រកបដោយវិបាក មិនដល់នូវការសន្សំកពូនឡើងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ អរិយធម្មវិបាកកថា ។

# វិបាកវិបាកធម្មធម្មោតិកថា

[៧៤២] *វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។*

តស្ស វិបាកោ វិបាកធម្មធម្មោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តស្ស វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ តស្ស តស្សេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៤៣] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ វិបាកោតិ វា វិបាកធម្មធម្មោតិ វា វិបាកធម្មធម្មោតិ វា វិបាកោតិ វា ឯសេ សេ ឯកដ្ឋេ សមេ សម-ភាគេ តជ្ជាតេតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៤៤] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ វិបាកោ ច វិបាកធម្មធម្មោ ច វិបាកធម្មធម្មោ ច វិបាកោ ច សហគតា សហជាតា សំសដ្ឋា សម្ប-យុត្តា ឯកុប្បាទា ឯកនិរោធា ឯកវត្ថុកា ឯការម្ម-ណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៤៥] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ តញ្ញេវ អកុសលំ សោ អកុសលស្ស វិបាកោ តញ្ញេវ កុសលំ សោ កុសលស្ស វិបាកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

វិបាក នៃធម៌ដែលមានវិបាកជាប្រក្រតីនោះ ជាធម៌មានវិបាកជាប្រក្រតី ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិបាក នៃធម៌ដែលមានវិបាកជាប្រក្រតីនោះ ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ ការធ្វើនូវទីបំផុត នៃទុក្ខនោះៗ មិនមាន ការផ្តាច់បង់នូវវដ្តៈ មិនមាន ការរំលត់នូវអនុបាទា មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៣] វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ ធម៌គឺវិបាកក្តី ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មានវិបាកជាប្រក្រតីក្តី វិបាកក្តី នុ៎ះជាធម៌តាំងនៅជាមួយគ្នា ស្មើគ្នា មានចំណែកស្មើ កើតជាមួយនឹងធម៌នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៤] វិបាក ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ វិបាកក្តី ធម៌មានវិបាកជាប្រក្រតីក្តី ធម៌មានវិបាកជាប្រក្រតីក្តី វិបាកក្តី ជាធម៌ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា ច្រឡំព្រម ប្រកបព្រម កើតជាមួយគ្នា រលត់ជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៥] វិបាក ជាធម៌មានវិបាកជាប្រក្រតីឬ ។ អើ ។ អកុសលនោះឯង ជាវិបាកនៃអកុសលនោះ កុសលនោះឯង ជាវិបាកនៃកុសលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៦] វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ យថេវ ចិត្តេន បាណំ ហនតិ តថេវ ចិត្តេន និរយេ បច្ចតិ យថេវ ចិត្តេន ទានំ ទេតិ តថេវ ចិត្តេន សគ្គេ មោទតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៤៧] ន វត្តព្វំ វិបាកោ វិបាកធម្មធម្មោតិ ។ អាមន្តា ។ ននុ វិបាកា ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញប្បច្ចយាតិ ។ អាមន្តា ។ ហញ្ចិ វិបាកា ចត្តារោ ខន្ធា អរូបិនោ អញ្ញមញ្ញប្បច្ចយា តេន វត រេ វត្តព្វេ វិបាកោ វិបាកធម្មធម្មោតិ ។

វិបាកោ វិបាកធម្មធម្មោតិកថា ។

សត្តមោ វគ្គោ ។

# តស្ស ឧទ្ទានំ

សង្គហោ សម្បយោគោ ចេតសិកោ ធម្មោ ចេតសិកំ ទានំ បរិភោគមយំ បុញ្ញំ វឌ្ឍតិ ឥតោ ទិន្នេន តត្ថ យាបេន្តិ បឋវី កម្មវិបាកោ ជរាមរណំ វិបាកោ នត្ថិ អរិយធម្មវិបាកោ វិបាកោ វិបាកធម្មធម្មោតិ ។

[៧៤៦] វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីឬ ។ អើ ។ បុគ្គល សម្លាប់សត្វដោយចិត្តណា រមែងឆេះនៅក្នុងនរក ដោយចិត្តនោះឯង ឲ្យទានដោយចិត្តណា រមែងរីករាយក្នុងឋានសួគ៌ ដោយចិត្តនោះឯងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៤៧] បុគ្គលមិនគួរនិយាយថា វិបាក ជាធម៌ដែលមានវិបាកជាប្រក្រតីទេឬ ។ អើ ។ ក្រែង វិបាកទាំងឡាយ ជាខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដល់គ្នានិងគ្នាឬ ។ អើ ។ បើវិបាកទាំងឡាយ ជាខន្ធ ៤ ដែលមិនមានរូប ជាបច្ច័យដល់គ្នានិងគ្នា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វិបាក ជាធម៌មានវិបាកជាប្រក្រតី ។

ចប់ វិបាកវិបាកធម្មធម្មោតិកថា ។

ចប់ សត្តមវគ្គ ។

# ឧទ្ទាននៃសត្តមវគ្គនោះ គឺ

និយាយអំពី ការសង្គ្រោះ ១ ការប្រកបព្រម ១ ធម៌ប្រព្រឹត្តទៅក្នុងចិត្ត ១ ទានប្រព្រឹត្តទៅក្នុងចិត្ត ១ បុណ្យ សម្រេចដោយការបរិភោគ តែងចម្រើន ១ ពួកប្រេត ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ក្នុងបិត្តិវិស័យនោះ ដោយទានដែលញាតិឲ្យហើយ អំពីលោកនេះ ១ ប្រឹថពី ជាវិបាកនៃកម្ម ១ ជរានិងមរណៈ ជាវិបាក ១ វិបាកនៃអរិយធម៌ មិនមាន ១ វិបាក ជាធម៌មានវិបាកជាប្រក្រតី ១ ។

៣០៩

# ឆគតិកថា

[៧៤៨] ឆ គតិយោតិ ។ អាមន្តា ។ ននុ បញ្ច គតិយោ វុត្តា ភគវតា និរយោ តិរច្ឆានយោនិ បិត្តិវិសយោ មនុស្សា ទេវាតិ ។ អាមន្តា ។ ហញ្ចិ បញ្ច គតិយោ វុត្តា ភគវតា និរយោ តិរច្ឆានយោនិ បិត្តិវិសយោ មនុស្សា ទេវា នោ វត រេ វត្តព្វេ ឆ គតិយោតិ ។

[៧៤៩] ឆ គតិយោតិ ។ អាមន្តា ។ ននុ កាលកញ្ជិកា អសុរា បេតានំ សមានវណ្ណា[១] សមានភោគា សមានាហារា សមានាយុកា បេតេហិ សហ អាវាហវិវាហំ គច្ឆន្តីតិ ។ អាមន្តា ។ ហញ្ចិ កាលកញ្ជិកា អសុរា បេតានំ សមានវណ្ណា សមា-នភោគា សមានាហារា សមានាយុកា បេតេហិ សហ អាវាហវិវាហំ គច្ឆន្តិ នោ វត រេ វត្តព្វេ ឆ គតិយោតិ ។

[៧៥០] ឆ គតិយោតិ ។ អាមន្តា ។ ននុ វេបចិត្តិបរិសា ទេវានំ សមានវណ្ណា សមានភោគា

១ ឯត្ថន្តរេ វិភច្ឆាតិ អដ្ឋកថាយំ ទិស្សតិ; វិរូបា ទុទ្ទសិកាតិ តស្សត្ថោ ។

# ឆគតិកថា

[៧៤៨] គតិ មាន ៦ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គតិ មាន ៥ គឺ នរក ១ កំណើតសត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គតិ មាន ៥ គឺ នរក ១ កំណើតសត្វតិរច្ឆាន ១ បិត្តិវិស័យ ១ មនុស្ស ១ ទេវតា ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ មាន ៦ ទេ ។

[៧៤៩] គតិ មាន ៦ ឬ ។ អើ ។ ក្រែងពួកកាលកញ្ជិកាសុរ មានវណ្ណៈស្មើគ្នា មានភោគៈគឺមេថុនស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកប្រេត ទៅកាន់អាវាហៈនិងវិវាហៈជាមួយនឹងពួកប្រេតដែរឬ ។ អើ ។ ប្រសិនបើ ពួកកាលកញ្ជិកាសុរ មានវណ្ណៈស្មើគ្នា មានភោគៈគឺមេថុនស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកប្រេត ទៅកាន់អាវាហៈនិងវិវាហៈជាមួយនឹងពួកប្រេត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិ មាន ៦ ទេ ។

[៧៥០] គតិ មាន ៦ ឬ ។ អើ ។ ក្រែង ពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ មានវណ្ណៈស្មើគ្នា មានភោគៈគឺបញ្ចកាមគុណស្មើគ្នា

សមានាហារា សមានាយុកា ទេវេហិ សហ អាវាហវិវាហំ គច្ឆន្តីតិ ។ អាមន្តា ។ ហញ្ចិ វេបចិត្តិបរិសា ទេវានំ សមានវណ្ណា សមានភោគា សមានាហារា សមានាយុកា ទេវេហិ សហ អាវាហវិវាហំ គច្ឆន្តិ នោ វត រេ វត្តព្វេ ឆ គតិយោតិ ។

[៧៨១] ឆ គតិយោតិ ។ អាមន្តា ។ ននុ វេបចិត្តិបរិសា បុព្វទេវាតិ ។ អាមន្តា ។ ហញ្ចិ វេបចិត្តិបរិសា បុព្វទេវា នោ វត រេ វត្តព្វេ ឆ គតិយោតិ ។

[៧៨២] ន វត្តព្វំ ឆ គតិយោតិ ។ អាមន្តា ។ ននុ អត្ថិ អសុរកាយោតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អសុរកាយោ តេន វត រេ វត្តព្វេ ឆ គតិយោតិ ។

ឆគតិកថា ។

## អន្តរាភវកថា

[៧៨៣] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ កាមភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ រូបភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកទេវតា ទៅកាន់អាវាហៈនិងវិវាហៈជាមួយនឹងពួកទេវតាដែរឬ ។ អើ ។ ប្រសិនបើ ពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ មានវណ្ណៈស្មើគ្នា មានភោគៈគឺបញ្ចកាមគុណស្មើគ្នា មានអាហារស្មើគ្នា មានអាយុស្មើគ្នានឹងពួកទេវតា ទៅកាន់អាវាហៈនិងវិវាហៈជាមួយនឹងពួកទេវតា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិមាន ៦ ទេ ។

[៧៩១] គតិ មាន ៦ ឬ ។ អើ ។ ក្រែង ពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ ជាទេវតាដើមឬ ។ អើ ។ ប្រសិនបើ ពួកបរិស័ទរបស់ព្រះបាទវេបចិត្តិ ជាទេវតាដើម ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គតិមាន ៦ ទេ ។

[៧៩២] បុគ្គលមិនគួរនិយាយថា គតិ មាន ៦ ទេឬ ។ អើ ។ ក្រែងអសុរកាយ មានដែរឬ ។ អើ ។ ប្រសិនបើ អសុរកាយ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គតិ មាន ៦យ៉ាង ។

ចប់ ឆគតិកថា ។

# អន្តរាភវកថា

[៧៩៣] អន្តរាភព (ភពដែលមានក្នុងចន្លោះឬក្នុងរវាង) មានឬ ។ អើ ។ គឺកាមភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព មានឬ ។ អើ ។ គឺរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អរូបភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៩៤] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ កាម-ភវស្ស ច រូបភវស្ស ច អន្តរេ អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ រូបភវស្ស ច អរូបភវស្ស ច អន្តរេ អត្ថិ អន្តរាភវោ-តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៩៥] កាមភវស្ស ច រូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ កាមភវស្ស ច រូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោ នោ វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។ រូបភវស្ស ច អរូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ រូបភវស្ស ច អរូបភវស្ស ច អន្តរេ នត្ថិ អន្តរាភវោ នោ វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

[៧៩៦] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ បញ្ចមី សា យោនិ ឆដ្ឋមី[១] សា គតិ អដ្ឋមី សា វិញ្ញាណដ្ឋិតិ ។

១ ម. ឆដ្ឋី ។

អន្តរាភព មានឬ ។ អើ ។ គឺអរូបភពឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។ បេ ។

[៧៥៤] អន្តរាភព មានឬ ។ អើ ។ អន្តរាភព មាន ក្នុង ចន្លោះនៃកាមភពនិងរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព មានឬ ។ អើ ។ អន្តរាភព មាន ក្នុងចន្លោះនៃរូបភពនិង អរូបភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៥៥] អន្តរាភព មិនមាន ក្នុងចន្លោះនៃកាមភពនិងរូបភពទេ ឬ ។ អើ ។ ប្រសិនបើ អន្តរាភព មិនមាន ក្នុងចន្លោះនៃកាមភពនិង រូបភពទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។ អន្តរាភព មិនមាន ក្នុងចន្លោះ នៃរូបភពនិងអរូបភពទេឬ ។ អើ ។ ប្រ-សិនបើ អន្តរាភព មិនមាន ក្នុងចន្លោះ នៃរូបភពនិងអរូបភពទេ ម្នាល អ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

[៧៥៦] អន្តរាភព មានឬ ។ អើ ។ គឺកំណើតជា គម្រប់ ៥ នោះ គតិជាគម្រប់ ៦ នោះ វិញ្ញាណដ្ឋិតិជាគម្រប់ ៨ នោះ

ឧសមោ សោ សត្តាវាសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អន្តរាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អន្តរាភវូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាភវោ បញ្ចវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៨៧] អត្ថិ កាមភវោ កាមភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អត្ថិ អន្តរាភវោ អន្តរាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមភវូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អន្តរាភវូបគំ កម្មន្តិ ។

សត្តាវាសៈជាគម្រប់ ១០ នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព មានឬ ។ អើ ។ អន្តរាភព គឺភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វតែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៩៧] កាមភព រមែងមាន ចុះកាមភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព(មាន)ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងកាមភព មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមករូបកា សត្តា-
តិ ។ អាមន្តា ។ អត្ថិ អន្តរាករូបកា សត្តាតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ កាមភវេ សត្តា ជាយន្តិ
ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តិ ។ អាមន្តា ។ អន្តរា-
ភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧប-
បជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមភវេ អត្ថិ
រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណាន្តិ ។ អាមន្តា ។
អន្តរាភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណាន្តិ ។
ន ហេវំ វត្តព្វេ ។ បេ ។ កាមភវោ បញ្ចវោការភវោតិ ។
អាមន្តា ។ អន្តរាភវោ បញ្ចវោការភវោតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

[៧៤៨] អត្ថិ រូបភវោ រូបភវោ ភវោ គតិ
សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភា-
វប្បដិលាភោតិ ។ អាមន្តា ។ អត្ថិ អន្តរាភវោ អន្ត-
រាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ
វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ អត្ថិ រូបករូបកំ កាម្មន្តិ ។ អាមន្តា ។ អត្ថិ
អន្តរាករូបកំ កាម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ ចូលទៅកើតក្នុងកាមភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងកាមភពដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមភព គឺបញ្ចវោការភពឬ ។ អើ ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៥៨] រូបភព រមែងមាន ចុះរូបភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន) ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងរូបភព មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អត្ថិ រូបករូបកា សត្តាតិ ។ អាមន្តា ។ អត្ថិ អន្តរាករូបកា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបកវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អន្តរាភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អន្តរាភវេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបភវោ បញ្ចវោការភវោតិ ។ អាមន្តា ។ អន្តរាភវោ បញ្ចវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៨៩] អត្ថិ អរូបភវោ អរូបភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អត្ថិ អន្តរាភវោ អន្តរាភវោ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរូបករូបកំ កម្មន្តិ ។ អាមន្តា ។ អត្ថិ អន្តរាករូបកំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពួកសត្វ ចូលទៅកើតក្នុងរូបភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងរូបភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងរូបភពដែរឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូបភព គឺបញ្ចវោការភពឬ ។ អើ ។ អន្តរាភព គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៥៩] អរូបភព រមែងមាន ចុះអរូបភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន) ដែរឬ ។ អើ ។ អន្តរាភព រមែងមាន ចុះអន្តរាភព ភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាព (មាន)ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អត្ថិ អរូបភរូបកា សត្តាតិ ។ អាមន្តា ។ អត្ថិ អន្ត-រាភរូបកា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ អន្តរាភវេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបភវេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ អន្តរាភវេ អត្ថិ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបភវោ ចតុវោការភវោតិ ។ អាមន្តា ។ អន្តរាភវោ ចតុវោការភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៦០] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ សព្វេសញ្ញេវ សត្តានំ អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វេសញ្ញេវ សត្តានំ នត្ថិ អន្តរា-ភវោតិ ។ អាមន្តា ។ ហញ្ចិ សព្វេសញ្ញេវ សត្តានំ នត្ថិ អន្តរាភវោ នោ វត វេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

ពួកសត្វ ចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងអន្តរាភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអរូបភពដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអរូបភពដែរឬ ។ អើ ។ វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងអន្តរាភពដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរូបភព គឺចតុវោការភពឬ ។ អើ ។ អន្តរាភព គឺចតុវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៦០] អន្តរាភព មានដែរឬ ។ អើ ។ អន្តរាភព របស់ពួកសត្វទាំងអស់ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់ពួកសត្វទាំងអស់ មិនមានទេឬ ។ អើ ។ ប្រសិនបើអន្តរាភព របស់ពួកសត្វទាំងអស់ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

[៧៦១] អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អានន្តរិយស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរាភវោ នោ ច វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

[៧៦២] ន អានន្តរិយស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អានន្តរិយស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ អា-មន្តា ។ ន អានន្តរិយស្ស បុគ្គលស្ស នត្ថិ អន្តរា-ភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ និរយូបគស្ស បុគ្គលស្ស ។ បេ ។ អសញ្ញសត្តូបគស្ស បុគ្គលស្ស ។ បេ ។ អរូបូបគស្ស បុគ្គលស្ស អត្ថិ អន្តរាភវោ-តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបូបគស្ស បុគ្គ-លស្ស នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ហញ្ចិ អរូបូបគស្ស បុគ្គលស្ស នត្ថិ អន្តរាភវោ នោ ច វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។

[៧៦១] អន្តរាភព មានដែរឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

[៧៦២] អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមានទេឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកធ្វើអនន្តរិយកម្ម មិនមែនជាមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងនរក (មាន) ។ បេ ។ របស់បុគ្គលអ្នកចូលទៅកើតក្នុងអសញ្ញសត្វ (មាន) ។ បេ ។ របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេឬ ។ អើ ។ ប្រសិនបើ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។

៣១៧

អន្តរាភវកថា

[៧៦៣] ន អរូបូបគស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អរូបូបគស្ស បុគ្គលស្ស អត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរូបូបគស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ន អរូបូបគស្ស បុគ្គលស្ស នត្ថិ អន្តរាភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៦៤] ន វត្តព្វំ អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ននុ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថីតិ ។ អាមន្តា ។ ហញ្ចិ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថិ តេន វត រេ វត្តព្វេ អត្ថិ អន្តរាភវោតិ ។ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ ឧបហច្ចបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ ឧបហច្ចភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អន្តរាបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ អន្តរាភវោតិ ។ អាមន្តា ។ អសង្ខារបរិនិព្វាយី បុគ្គលោ ។ បេ ។ សសង្ខារបរិនិព្វាយី បុគ្គលោ អត្ថីតិ កត្វា អត្ថិ សសង្ខារភវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អន្តរាភវកថា ។

អន្តរាភវកថា

*[៧៦៣] អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេឬ ។ អើ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមានទេឬ ។ អើ ។ អន្ត-រាភព របស់បុគ្គលអ្នកចូលទៅកើតក្នុងអរូបភព មិនមែនជាមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

*[៧៦៤] បុគ្គលមិនគួរនិយាយថា អន្តរាភព មានទេឬ ។ អើ ។ ក្រែង បុគ្គល ជាអន្តរាបរិនិព្វាយី មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គល ជាអន្តរាបរិនិព្វាយី មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អន្តរាភព មានទេ ។ អន្តរាភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាអន្តរាបរិនិព្វាយី មានឬ ។ អើ ។ ឧបហច្ចភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាឧបហច្ចបរិនិព្វាយី មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អន្តរាភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាអន្តរាបរិនិព្វាយី មានឬ ។ អើ ។ បុគ្គល ជាអសង្ខារបរិនិព្វាយី ។ បេ ។ សសង្ខារភព មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តថា បុគ្គល ជាសសង្ខារបរិនិព្វាយី មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ អន្តរាភវកថា ។

# កាមគុណកថា

[៧៦៥] បញ្ចេវ កាមគុណា កាមធាតូតិ ។ អាមន្តា ។ ននុ អត្ថិ តប្បដិសំយុត្តោ ឆន្ទោតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ តប្បដិសំយុត្តោ ឆន្ទោ នោ វត រេ វត្តព្វេ បញ្ចេវ កាមគុណា កាមធាតូតិ ។ ននុ អត្ថិ តប្បដិសំយុត្តោ រាគោ តប្បដិសំយុត្តោ ឆន្ទរាគោ តប្បដិសំយុត្តោ សង្កប្បោ តប្បដិសំយុត្តោ រាគោ តប្បដិសំយុត្តោ សង្កប្បរាគោ តប្បដិសំយុត្តា បីតិ តប្បដិសំយុត្តំ សោមនស្សំ តប្បដិសំយុត្តំ បីតិ-សោមនស្សន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ តប្បដិសំ-យុត្តំ បីតិសោមនស្សំ នោ វត រេ វត្តព្វេ បញ្ចេវ កាមគុណា កាមធាតូតិ ។

[៧៦៦] បញ្ចេវ កាមគុណា កាមធាតូតិ ។ អា-មន្តា ។ មនុស្សានំ ចក្ខុំ ន កាមធាតូតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនុស្សានំ សោតំ ។ បេ ។ មនុស្សានំ ឃានំ ។ បេ ។ មនុស្សានំ ជិវ្ហា ។ បេ ។ មនុស្សានំ កាយោ ។ បេ ។ មនុស្សានំ មនោ ន កាមធាតូតិ ។

# កាមគុណកថា

[៧៦៥] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ ក្រែង ឆន្ទៈ ប្រកបដោយកាមគុណនោះ មានដែរឬ ។ អើ ។ ប្រសិនបើ ឆន្ទៈ ប្រកបដោយកាមគុណនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នក មិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេ ក្រែងរាគៈ ប្រកប ដោយកាមគុណនោះ ឆន្ទរាគៈ ប្រកបដោយកាមគុណនោះ សង្កប្បៈ ប្រកបដោយកាមគុណនោះ រាគៈ ប្រកបដោយកាមគុណនោះ សង្កប្ប-រាគៈ ប្រកបដោយកាមគុណនោះ បីតិ ប្រកបដោយកាមគុណនោះ សោមនស្ស ប្រកបដោយកាមគុណនោះ បីតិសោមនស្ស ប្រកបដោយ កាមគុណនោះ មានដែរឬ ។ អើ ។ ប្រសិនបើ បីតិសោមនស្ស ប្រកបដោយកាមគុណនោះ មានមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរ ពោលថា កាមគុណ ៥ ជាកាមធាតុទេ ។

[៧៦៦] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ ចក្ខុ របស់ ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ត្រចៀក របស់ពួកមនុស្ស ។ បេ ។ ច្រមុះ របស់ពួកមនុស្ស ។ បេ ។ អណ្តាត របស់ពួកមនុស្ស ។ បេ ។ កាយ របស់ពួកមនុស្ស ។ បេ ។ ចិត្ត របស់ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អ្នក

ន ហេវំ វត្តព្វេ ។ បេ ។ មនុស្សានំ មនោ ន កាម-
ជាតូតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

បញ្ច កាមគុណា លោកេ មនោឆដ្ឋា បវេទិតា
ឯត្ថ ឆន្ទំ វិរាជេត្វា ឯវំ ទុក្ខា បមុច្ចតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ
មនុស្សានំ មនោ ន កាមជាតូតិ ។

[៧៦៧] បញ្ចេវ កាមគុណា កាមជាតូតិ ។
អាមន្តា ។ កាមគុណា ភវោ គតិ សត្តាវាសោ
សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមគុណូបគំ
កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាម-
គុណូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
កាមគុណេ សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ
ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមគុណេ
អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ កាមគុណា បញ្ចវោការភវោតិ ។

មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចិត្ត របស់ពួកមនុស្ស មិនមែនជាកាមធាតុទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

កាមគុណ ៥ មានចិត្តជាគម្រប់ ៦ តថាគត សម្តែងទុក
ក្នុងលោក បុគ្គល កម្ចាត់បង់ឆន្ទៈ ក្នុងកាមគុណទាំងនុ៎ះ រមែង
រួចចាកទុក្ខ ដោយហេតុយ៉ាងនេះឯង

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ចិត្ត របស់ពួកមនុស្ស មិនមែនជាកាមធាតុទេ ។

[៧៦៧] កាមគុណ ៥ ជាកាមធាតុឬ ។ អើ ។ កាមគុណ គឺភព គតិ សត្តាវាសៈ សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ ចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមគុណ គឺបញ្ចវោការភពឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ កាមគុណេ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ សាវកយុគំ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមធាតុ ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិ-តិ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ កាមគុណា ភវោ គតិ សត្តាវាសោ សំសារោ យោនិ វិញ្ញាណដ្ឋិតិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមធាតូបគំ កម្មន្តិ ។ អាមន្តា ។ អត្ថិ កាមគុណូបគំ កម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កាមធាតូបគា សត្តាតិ ។ អាមន្តា ។ អត្ថិ កាមគុណូបគា សត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមធាតុយា សត្តា ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ អាមន្តា ។ កាមគុណេ សត្តា ជា-យន្តិ ជិយ្យន្តិ មិយ្យន្តិ ចវន្តិ ឧបបជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមធាតុយា អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ អាមន្តា ។ កាមគុណេ អត្ថិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមធាតុ បញ្ចវោការភវោតិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើង ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើតឡើង គូនៃសាវ័ក កើតឡើង ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមធាតុ គឺភព គតិ សត្តាវាស: សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អើ ។ កាមគុណ គឺភព គតិ សត្តាវាស: សំសារ កំណើត វិញ្ញាណដ្ឋិតិ និងការបានចំពោះនូវអត្តភាពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្ម នាំចូលទៅកើតក្នុងកាមធាតុ មានដែរឬ ។ អើ ។ កម្ម នាំចូលទៅកើតក្នុងកាមគុណមានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ ចូលទៅកើតក្នុងកាមធាតុ មានដែរឬ ។ អើ ។ ពួកសត្វ ចូលទៅកើតក្នុងកាមគុណ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមធាតុដែរឬ ។ អើ ។ ពួកសត្វ តែងកើត ចាស់ ស្លាប់ ច្យុត បដិសន្ធិ ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មានក្នុងកាមធាតុឬ ។ អើ ។ រូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណ មាន ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមធាតុ ជាបញ្ចវោការភពឬ ។

អាមន្តា ។ កាមគុណា បញ្ចហោការកហោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមជាតុយា សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ សាវកយុគំ ឧប្ប-ជ្ជតីតិ ។ អាមន្តា ។ កាមគុណោ សម្មាសម្ពុទ្ធា ឧប្បជ្ជន្តិ បច្ចេកសម្ពុទ្ធា ឧប្បជ្ជន្តិ សាវកយុគំ ឧប្ប-ជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៦៨] ន វត្តព្វំ បញ្ចេវ កាមគុណា កាមជាតូ-តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា ។ កតមេ បញ្ច ។ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជ-នីយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ។ បេ ។ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ កាយ-វិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចេវ កាមគុណា កាមជាតូតិ ។

អើ ។ កាមគុណ គឺបញ្ចវោការភពឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើង ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើតឡើង គូនៃសាវ័ក កើតឡើង ក្នុងកាមធាតុដែរឬ ។ អើ ។ ព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើង ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ កើតឡើង គូនៃសាវ័ក កើតឡើង ក្នុងកាមគុណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧៦៨] បុគ្គលមិនគួរពោលថា កាមគុណ ៥ ជាកាមធាតុទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ កាមគុណនេះ មាន ៥ យ៉ាង ។ កាមគុណ ៥ យ៉ាង តើដូចម្តេច ។ គឺរូបទាំងឡាយ ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម គួររីករាយ ១ សំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ។ បេ ។ ក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ ។ បេ ។ រសទាំងឡាយ ដែលគប្បីដឹងដោយអណ្តាត ។ បេ ។ ផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម គួររីករាយ ១ ម្នាលភិក្ខុទាំងឡាយ កាមគុណ មាន ៥ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ កាមគុណ៥ យ៉ាង ជាកាមធាតុ (ដោយពិត) ។

ចប់ កាមគុណកថា ។

# កាមកថា

ហញ្ចិ អនាគតារម្មណំ ឆោ វត វេ វត្តព្វេ អនាគ-
តារម្មណំ ចិត្តំ អនារម្មណន្តិ អនាគតារម្មណំ ចិត្តំ
អនារម្មណន្តិ មិច្ឆា ហញ្ចិ វា បន អនារម្មណំ ឆោ
វត វេ វត្តព្វេ អនាគតារម្មណន្តិ អនារម្មណំ
អនាគតារម្មណន្តិ មិច្ឆា ។

[៩០១] អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។
អាមន្តា ។ ននុ អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។
បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនាគតំ អារព្ភ អត្ថិ
អាវជ្ជនា ។ បេ ។ បណិធិ ឆោ វត វេ វត្តព្វេ
អនាគតារម្មណំ ចិត្តំ អនារម្មណន្តិ ។

[៩០២] បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។
បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ សារម្មណន្តិ ។ អាមន្តា ។
អតីតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អតីតា-
រម្មណំ ចិត្តំ សារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ប្រសិនបើ (ចិត្ត) មានអារម្មណ៍ជាអនាគត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ (ព្រោះពាក្យថា) ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ ដូច្នេះ ជាពាក្យខុស មួយទៀត ប្រសិនបើ ចិត្ត មិនមានអារម្មណ៍ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត មានអារម្មណ៍ជាអនាគតទេ (ព្រោះពាក្យថា) មិនមានអារម្មណ៍ និងមានអារម្មណ៍ជាអនាគត ដូច្នេះ ជាពាក្យខុស ។

[៩០១] ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគតឬ ។ អើ ។ ប្រសិនបើ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ។

[៩០២] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ (មានអារម្មណ៍ជាបច្ចុប្បន្ន) ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ចុះចិត្ត ជាអតីតារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អនាគតារម្មណកថា

[៩០៣] បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ សារម្មណាន្តិ ។ អាមន្តា ។ អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អនាគតារម្មណំ ចិត្តំ សារម្មណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៤] អតីតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អតីតារម្មណំ ចិត្តំ អនារម្មណាន្តិ ។ អាមន្តា ។ បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នា-រម្មណំ ចិត្តំ អនារម្មណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៥] អនាគតំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ អនាគតារម្មណំ ចិត្តំ អនារម្មណាន្តិ ។ អា-មន្តា ។ បច្ចុប្បន្នំ អារព្ភ អត្ថិ អាវជ្ជនា ។ បេ ។ បណិធិ បច្ចុប្បន្នារម្មណំ ចិត្តំ អនារម្មណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៦] ន វត្តព្វំ អតីតានាគតារម្មណំ ចិត្តំ អនារម្មណាន្តិ ។ អាមន្តា ។ ននុ អតីតានាគតំ នត្ថីតិ ។ អាមន្តា ។ ហញ្ចិ អតីតានាគតំ នត្ថិ

អនាគតារម្មណកថា

[៩០៣] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ចុះចិត្ត ជាអនាគតារម្មណ៍ ប្រកបដោយអារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៤] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអតីត ចុះចិត្ត ជាអតីតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៥] ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវអនាគត ចុះចិត្ត ជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក មាន ព្រោះប្រារព្ធនូវបច្ចុប្បន្ន ចុះចិត្ត ជាបច្ចុប្បន្នារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៦] បុគ្គលមិនគួរនិយាយថា ចិត្ត ជាអតីតារម្មណ៍ និងជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេឬ ។ អើ ។ ក្រែងអតីត និងអនាគត មិនមានទេឬ ។ អើ ។ ប្រសិនបើ អតីតនិងអនាគត មិនមានទេ

តេន វត រេ វត្តព្វេ អតីតានាគតារម្មណំ ចិត្តំ អនា-
រម្មណន្តិ ។ បេ ។

អនាគតារម្មណកថា ។

# វិតក្កានុបតិតកថា

[៩០៧] សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ សព្វំ ចិត្តំ វិចារានុបតិតំ បីតានុបតិតំ សុខានុបតិតំ ទុក្ខានុបតិតំ សោមនស្សានុបតិតំ ទោមនស្សានុបតិ-
តំ ឧបេក្ខានុបតិតំ សទ្ធានុបតិតំ វីរិយានុបតិតំ សតា-
នុបតិតំ សមាធានុបតិតំ បញ្ញានុបតិតំ រាគានុបតិតំ ទោសានុបតិតំ ។ បេ ។ អនោត្តប្បានុបតិតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩០៨] សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ ននុ អត្ថិ អវិតក្កោ វិចារមត្តោ សមាធីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អវិតក្កោ វិចារមត្តោ សមាធិ នោ វត រេ វត្តព្វេ សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។

[៩០៩] សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ ននុ អត្ថិ អវិតក្កោ អវិចារោ សមាធីតិ ។ អាមន្តា ។

ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ចិត្ត ជាអតីតារម្មណ៍ និងជាអនាគតារម្មណ៍ មិនមានអារម្មណ៍ទេ ។ បេ ។

ចប់ អនាគតារម្មណកថា ។

# វិតក្កានុបតិតកថា

[៩០៧] ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ចិត្តទាំងអស់ ដែលវិចារ ជាប់តាម ដែលបីតិជាប់តាម ដែលសុខជាប់តាម ដែលទុក្ខជាប់តាម ដែលសោមនស្សជាប់តាម ដែលទោមនស្សជាប់តាម ដែលឧបេក្ខាជាប់តាម ដែលសទ្ធាជាប់តាម ដែលវីរិយៈជាប់តាម ដែលសតិជាប់តាម ដែលសមាធិជាប់តាម ដែលបញ្ញាជាប់តាម ដែលរាគៈជាប់តាម ដែលទោសៈជាប់តាម ។ បេ ។ ដែលអនោត្តប្បៈជាប់តាមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩០៨] ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ក្រែងសមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានដែរឬ ។ អើ ។ ប្រសិនបើ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមទេ ។

[៩០៩] ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ក្រែងសមាធិ មិនមានវិតក្កៈ មិនមានវិចារៈ មានដែរឬ ។ អើ ។

ហញ្ចិ អត្ថិ អវិតក្កោ អវិចារោ សមាធិ នោ វត រេ វត្តព្វេ សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។

[៩១០] សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។ អាមន្តា ។ ននុ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចា-រោ សមាធីតិ ។ អាមន្តា ។ ហញ្ចិ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធិ នោ វត រេ វត្តព្វេ សព្វំ ចិត្តំ វិតក្កានុបតិតន្តិ ។

វិតក្កានុបតិតកថា ។

# វិតក្កវិប្ផារសទ្ទកថា

[៩១១] សព្វសោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារោ សទ្ទោតិ ។ អាមន្តា ។ សព្វសោ ផុស-យតោ ផស្សវិប្ផារោ សទ្ទោ សព្វសោ វេទយតោ វេទ-នាវិប្ផារោ សទ្ទោ សព្វសោ សញ្ជានតោ សញ្ញាវិប្ផារោ

ប្រសិនបើ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមទេ ។

[៩១០] ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សមាធិ មាន ៣ គឺសមាធិ មានវិតក្កៈ មានទាំងវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានទាំងវិចារៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា សមាធិ មាន ៣ គឺសមាធិ មានវិតក្កៈ មានទាំងវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានទាំងវិចារៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចិត្តទាំងអស់ ដែលវិតក្កៈជាប់តាមទេ ។

ចប់ វិតក្កានុបតិតកថា ។

# វិតក្កវិប្ផារសទ្ទកថា

[៩១១] សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ឬ ។ អើ ។ សំឡេង ជាគ្រឿងផ្សាយចេញនៃផស្សៈ របស់បុគ្គលកាលពាល់ត្រូវ ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃវេទនា របស់បុគ្គលកាលទទួលអារម្មណ៍ ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃសញ្ញា របស់បុគ្គល

សទ្ទោ សព្វសោ ចេតយតោ ចេតនាវិប្ផារោ សទ្ទោ សព្វសោ ចិន្តយតោ ចិត្តវិប្ផារោ សទ្ទោ សព្វសោ សរតោ សតិវិប្ផារោ សទ្ទោ សព្វសោ បជានតោ បញ្ញាវិប្ផារោ សទ្ទោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩១២] សព្វសោ វិតក្កយតោ វិចារយតោ វិតក្ក-វិប្ផារោ សទ្ទោតិ ។ អាមន្តា ។ វិតក្កវិប្ផារោ សទ្ទោ សោតវិញ្ញេយ្យោ សោតស្មឹ បដិហញ្ញតិ សោតស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ វិតក្កវិប្ផារោ សទ្ទោ ន សោតវិញ្ញេយ្យោ ន សោតស្មឹ បដិហញ្ញតិ ន សោតស្ស អាបាថំ អាគច្ឆតីតិ ។ អា-មន្តា ។ ហញ្ចិ វិតក្កវិប្ផារោ សទ្ទោ ន សោតវិញ្ញេយ្យោ ន សោតស្មឹ បដិហញ្ញតិ ន សោតស្ស អាបាថំ អា-គច្ឆតិ នោ វត រេ វត្តព្វេ សព្វសោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារោ សទ្ទោតិ ។

វិតក្កវិប្ផារសទ្ទកថា ។

កាលចំណាំបាន ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃចេតនា របស់បុគ្គលកាលនឹក ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃចិត្ត របស់បុគ្គលកាលគិត ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃសតិ របស់បុគ្គលកាលរឭក ដោយសព្វគ្រប់ សំឡេង ជាគ្រឿងផ្សាយចេញនៃបញ្ញា របស់បុគ្គលកាលដឹង ដោយសព្វគ្រប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩១២] សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ឬ ។ អើ ។ សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេង ដែលគួរដឹងបានដោយត្រចៀក ប៉ះទង្គិចក្នុងត្រចៀក មកកាន់គន្លងនៃត្រចៀកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេង មិនគួរដឹងដោយត្រចៀក មិនប៉ះទង្គិចក្នុងត្រចៀក មិនមកកាន់គន្លងនៃត្រចៀកទេឬ ។ អើ ។ ប្រសិនបើ សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ ជាសំឡេង ដែលមិនគួរដឹងដោយត្រចៀក មិនប៉ះទង្គិចក្នុងត្រចៀក មិនមកកាន់គន្លងនៃត្រចៀកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ទេ ។

ចប់ វិតក្កវិប្ផារសទ្ទកថា ។

# នយថាចិត្តស្ស វាចាតិកថា

[៩១៣] នយថាចិត្តស្ស វាចាតិ ។ អាមន្តា ។ អផស្សកស្ស វាចា អវេទនកស្ស វាចា អសញ្ញកស្ស វាចា អចេតនកស្ស វាចា អចិត្តកស្ស វាចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ សផស្សកស្ស វាចា សវេទនកស្ស វាចា សសញ្ញកស្ស វាចា សចេតនកស្ស វាចា សចិត្តកស្ស វាចាតិ ។ អាមន្តា ។ ហញ្ចិ សផស្សកស្ស វាចា ។ បេ ។ សចិត្តកស្ស វាចា នោ វត រេ វត្តព្វេ នយថាចិត្តស្ស វាចាតិ ។

[៩១៤] នយថាចិត្តស្ស វាចាតិ ។ អាមន្តា ។ អនាវជ្ជន្តស្ស វាចា អនាភោគស្ស វាចា ។ បេ ។ អបណិទហន្តស្ស វាចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អាវជ្ជន្តស្ស វាចា អាភោគស្ស វាចា ។ បេ ។ បណិទហន្តស្ស វាចាតិ ។ អាមន្តា ។ ហញ្ចិ អាវជ្ជន្តស្ស វាចា អាភោគស្ស វាចា ។ បេ ។ បណិទហន្តស្ស វាចា នោ វត រេ វត្តព្វេ នយថាចិត្តស្ស វាចាតិ ។

# នយថាចិត្តស្ស វាចាតិកថា

[៩១៣] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ វាចា របស់បុគ្គលមិនមានផស្សៈ វាចា របស់បុគ្គលមិនមានវេទនា វាចា របស់បុគ្គលមិនមានសញ្ញា វាចា របស់បុគ្គលមិនមានចេតនា វាចា របស់បុគ្គលមិនមានចិត្តឬ ។ មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងវាចា របស់បុគ្គលប្រកបដោយផស្សៈ វាចា របស់បុគ្គលប្រកបដោយវេទនា វាចា របស់បុគ្គលប្រកបដោយសញ្ញា វាចា របស់បុគ្គលប្រកបដោយចេតនា វាចា របស់បុគ្គលប្រកបដោយចិត្តឬ ។ អើ ។ ប្រសិនបើ វាចា របស់បុគ្គលប្រកបដោយផស្សៈ ។ បេ ។ វាចា របស់បុគ្គលប្រកបដោយចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

[៩១៤] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ វាចា របស់បុគ្គលកាលមិនពិចារណា វាចា របស់បុគ្គលកាលមិនសង្ឃឹម ។ បេ ។ វាចា របស់បុគ្គលកាលមិនតាំងចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង វាចា របស់បុគ្គលកាលពិចារណា វាចា របស់បុគ្គលកាលសង្ឃឹម ។ បេ ។ វាចា របស់បុគ្គលកាលតាំងចិត្តឬ ។ អើ ។ ប្រសិនបើ វាចា របស់បុគ្គលកាលពិចារណា វាចា របស់បុគ្គលកាលសង្ឃឹម ។ បេ ។ វាចា របស់បុគ្គលកាលតាំងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

[៩១៥] នយថាចិត្តស្ស វាចាតិ ។ អាមន្តា ។ ននុ វាចា ចិត្តសមុដ្ឋានា ចិត្តេន សហ ជាតា ចិត្តេន សហ ឯកុប្បាជាតិ ។ អាមន្តា ។ ហញ្ចិ វាចា ចិត្តសមុដ្ឋានា ចិត្តេន សហ ជាតា ចិត្តេន សហ ឯកុប្បាជា នោ វត រេ វត្តព្វេ នយថាចិត្តស្ស វាចាតិ ។

[៩១៦] នយថាចិត្តស្ស វាចាតិ ។ អាមន្តា ។ ន ភណិតុកាមោ ភណតិ ន កថេតុកាមោ កថេតិ ន អាលបិតុកាមោ អាលបតិ ន វោហរិតុកាមោ វោហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ភណិតុកាមោ ភណតិ កថេតុកាមោ កថេតិ អាលបិតុកាមោ អាលបតិ វោហរិតុកាមោ វោហរតីតិ ។ អាមន្តា ។ ហញ្ចិ ភណិតុកាមោ ភណតិ កថេតុកាមោ កថេតិ អាលបិតុកាមោ អាលបតិ វោហរិតុកាមោ វោហរតិ នោ វត រេ វត្តព្វេ នយថាចិត្តស្ស វាចាតិ ។

[៩១៧] ន វត្តព្វំ នយថាចិត្តស្ស វាចាតិ ។ អាមន្តា ។ ននុ អត្ថិ កោចិ អញ្ញំ ភណិស្សាមីតិ

[៩១៥] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ ក្រែងវាចា តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតឡើងព្រមគ្នានឹងចិត្តឬ ។ អើ ។ ប្រសិនបើ វាចា តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតឡើងព្រមគ្នានឹងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

[៩១៦] វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ បុគ្គល ចង់និយាយ តែមិននិយាយ ចង់ពោល តែមិនពោល ចង់ហៅ តែមិនហៅ ចង់ចរចា តែមិនចរចាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងបុគ្គល ចង់និយាយ តែងនិយាយបាន ចង់ពោល តែងពោលបាន ចង់ហៅ តែងហៅបាន ចង់ចរចា តែងចរចាបានឬ ។ អើ ។ ប្រសិនបើ បុគ្គល ចង់និយាយ តែងនិយាយបាន ចង់ពោល តែងពោលបាន ចង់ហៅ តែងហៅបាន ចង់ចរចា តែងចរចាបាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេ ។

[៩១៧] បុគ្គលមិនគួរនិយាយថា វាចា របស់បុគ្គលមិនពោលតាមចិត្តទេឬ ។ អើ ។ ក្រែងបុគ្គលទីមួយ គិតថា អាត្មាអញ នឹងនិយាយពាក្យដទៃ

អញ្ញំ ភណាតិ អញ្ញំ កាថេស្សាមីតិ អញ្ញំ កាថេតិ អញ្ញំ អាលបិស្សាមីតិ អញ្ញំ អាលបតិ អញ្ញំ វោហរិស្សាមីតិ អញ្ញំ វោហរតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណាតិ ។ បេ ។ អញ្ញំ វោហរិស្សាមីតិ អញ្ញំ វោហរតិ តេន វត រេ វត្តព្វេ នយថាចិត្តស្ស វាចាតិ ។

នយថាចិត្តស្ស វាចាតិកថា ។

## នយថាចិត្តស្ស កាយកម្មន្តិកថា

[៩១៨] នយថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ អផស្សកស្ស កាយកម្មំ ។ បេ ។ អចិត្តកស្ស កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ សផស្សកស្ស កាយកម្មំ ។ បេ ។ សចិត្តកស្ស កាយកម្មន្តិ ។ អាមន្តា ។ ហញ្ចិ សផស្សកស្ស កាយកម្មំ ។ បេ ។ សចិត្តកស្ស កាយកម្មំ នោ វត រេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

រមែងនិយាយពាក្យដទៃវិញ គិតថា អាត្មាអញ នឹងពោលពាក្យដទៃ រមែងពោលពាក្យដទៃវិញ គិតថា អាត្មាអញ នឹងហៅពាក្យដទៃ រមែងហៅពាក្យដទៃវិញ គិតថា អាត្មាអញ នឹងចរចាពាក្យដទៃ រមែងចរចាពាក្យដទៃវិញ មានឬ ។ អើ ។ ប្រសិនបើ បុគ្គលនីមួយ គិតថា អាត្មាអញ នឹងនិយាយពាក្យដទៃ រមែងនិយាយពាក្យដទៃវិញ ។ បេ ។ គិតថា អាត្មាអញ នឹងចរចាពាក្យដទៃ រមែងចរចាពាក្យដទៃវិញ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វាចា របស់បុគ្គលមិនពោលតាមចិត្ត ។

ចប់ នយថាចិត្តស្ស វាចាតិកថា ។

# នយថាចិត្តស្ស កាយកម្មន្តិកថា

[៩១៨] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេឬ ។ អើ ។ កាយកម្ម របស់បុគ្គលមិនមានផស្សៈ ។ បេ ។ កាយកម្ម របស់បុគ្គលមិនមានចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងកាយកម្ម របស់បុគ្គលប្រកបដោយផស្សៈ ។ បេ ។ កាយកម្ម របស់បុគ្គលប្រកបដោយចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម របស់បុគ្គលប្រកបដោយផស្សៈ ។ បេ ។ កាយកម្ម របស់បុគ្គលប្រកបដោយចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្មរបស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[៩១៩] នយថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ អជាវជ្ជន្តស្ស កាយកម្មំ ។ បេ ។ អបណិទហន្តស្ស កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អាវជ្ជន្តស្ស កាយកម្មំ ។ បេ ។ បណិទហន្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ហញ្ចិ អាវជ្ជន្តស្ស កាយកម្មំ ។ បេ ។ បណិទហន្តស្ស កាយកម្មំ នោ វត វេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

[៩២០] នយថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ននុ កាយកម្មំ ចិត្តសមុដ្ឋានំ ចិត្តេន សហ ជាតំ ចិត្តេន សហ ឯកុប្បាទន្តិ ។ អាមន្តា ។ ហញ្ចិ កាយកម្មំ ចិត្តសមុដ្ឋានំ ចិត្តេន សហ ជាតំ ចិត្តេន សហ ឯកុប្បាទំ នោ វត វេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

[៩២១] នយថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ន អភិក្កមិតុកាមោ អភិក្កមតិ ន បដិក្កមិតុកាមោ បដិក្កមតិ ន អាលោកេតុកាមោ អាលោកេតិ ន វិលោកេតុកាមោ វិលោកេតិ ន សម្មិញ្ជិតុកាមោ សម្មិញ្ជេតិ ន បសារេតុកាមោ បសារេតីតិ ។ ន ហេវំ

[៩១៩] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ កាយកម្ម របស់បុគ្គលកាលមិនពិចារណា ។ បេ ។ កាយកម្ម របស់បុគ្គលកាលមិនបានតាំងចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងកាយកម្ម របស់បុគ្គលកាលពិចារណា ។ បេ ។ កាយកម្ម របស់បុគ្គលកាលតាំងចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម របស់បុគ្គលកាលពិចារណា ។ បេ ។ កាយកម្ម របស់បុគ្គលកាលតាំងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[៩២០] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ ក្រែងកាយកម្ម តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតព្រមជាមួយនឹងចិត្តឬ ។ អើ ។ ប្រសិនបើ កាយកម្ម តាំងឡើងដោយចិត្ត កើតជាមួយនឹងចិត្ត កើតព្រមជាមួយនឹងចិត្ត (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[៩២១] កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តឬ ។ អើ ។ បុគ្គល ចង់ឈានទៅមុខ តែឈានទៅមុខមិនកើត ចង់ឈានថយក្រោយ តែឈានថយក្រោយមិនកើត ចង់ក្រឡេកទៅមុខ តែក្រឡេកទៅមុខមិនកើត ចង់ក្រឡេកទៅទិសផ្សេង ៗ តែក្រឡេកទៅទិសផ្សេងៗមិនកើត ចង់បត់អវយវៈចូល តែបត់អវយវៈចូលមិនកើត ចង់លាអវយវៈចេញ តែលាអវយវៈចេញមិនកើតឬ ។ អ្នកមិនគួរពោលយ៉ាង

វត្តព្វេ ។ បេ ។ ននុ អភិក្កមិតុកាមោ អភិក្កមតិ បដិក្កមិតុកាមោ បដិក្កមតិ អាលោកេតុកាមោ អាលោកេតិ វិលោកេតុកាមោ វិលោកេតិ សម្មិញ្ជិតុកាមោ សម្មិញ្ជេតិ បសារេតុកាមោ បសារេតីតិ ។ អាមន្តា ។ ហញ្ចិ អភិក្កមិតុកាមោ អភិក្កមតិ ។ បេ ។ បសារេតុកាមោ បសារេតិ នោ វត រេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

[៩២២] ន វត្តព្វំ នយថាចិត្តស្ស កាយកម្មន្តិ ។ អាមន្តា ។ ននុ អត្ថិ កោចិ អញ្ញត្រ គច្ឆិស្សាមីតិ អញ្ញត្រ គច្ឆតិ ។ បេ ។ អញ្ញំ បសារេស្សាមីតិ អញ្ញំ បសារេតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អញ្ញត្រ គច្ឆិស្សាមីតិ អញ្ញត្រ គច្ឆតិ ។ បេ ។ អញ្ញំ បសារេស្សាមីតិ អញ្ញំ បសារេតិ តេន វត រេ វត្តព្វេ នយថាចិត្តស្ស កាយកម្មន្តិ ។

នយថាចិត្តស្ស កាយកម្មន្តិកថា ។

នេះទេ ។ បេ ។ ក្រែងបុគ្គល ចង់ឈានទៅមុខ តែងឈានទៅមុខបាន ចង់ឈានថយក្រោយ តែងឈានថយក្រោយបាន ចង់ក្រឡេកទៅមុខ តែងក្រឡេកទៅមុខបាន ចង់ក្រឡេកទៅទិសផ្សេងៗ តែងក្រឡេកទៅទិសផ្សេងៗ បាន ចង់បត់អវយវៈចូល តែងបត់អវយវៈចូលបាន ចង់លាអវយវៈចេញ តែងលាអវយវៈចេញបានដែរឬ ។ អើ ។ ប្រសិនបើបុគ្គល ចង់ឈានទៅមុខ តែងឈានទៅមុខបាន ។ បេ ។ ចង់លាអវយវៈចេញ តែងលាអវយវៈចេញបាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេ ។

[៩២២] បុគ្គលមិនគួរនិយាយថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្តទេឬ ។ អើ ។ ក្រែងបុគ្គលទីមួយ គិតថា អាត្មាអញ នឹងទៅក្នុងទិសដទៃ តែត្រឡប់ជាទៅក្នុងទិសដទៃវិញ ។ បេ ។ គិតថា អាត្មាអញ នឹងលានូវអវយវៈដទៃ តែត្រឡប់ជាលានូវអវយវៈដទៃវិញ មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលទីមួយ គិតថា អាត្មាអញ នឹងទៅក្នុងទិសដទៃ តែត្រឡប់ជាទៅក្នុងទិសដទៃវិញ ។ បេ ។ គិតថា អាត្មាអញ នឹងលានូវអវយវៈដទៃ តែត្រឡប់ជាលានូវអវយវៈដទៃវិញ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្ត ។

ចប់ នយថាចិត្តកាយកម្មន្តិកថា ។

# អតីតានាគតប្បច្ចុប្បន្នកថា

[៩២៣] អតីតេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អតីតំ និរុទ្ធំ វិគតំ វិបរិណតំ អត្ថង្គតំ អព្ភត្ថង្គតន្តិ ។ អាមន្តា ។ ហញ្ចិ អតីតំ និរុទ្ធំ វិគតំ វិបរិណតំ អត្ថង្គតំ អព្ភត្ថង្គតំ នោ វត រេ វត្តព្វេ អតីតេន សមន្នាគតោតិ ។

[៩២៤] អនាគតេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគតំ អជាតំ អភូតំ អសញ្ជាតំ អនិព្វត្តំ អនភិនិព្វត្តំ អបាតុភូតន្តិ ។ អាមន្តា ។ ហញ្ចិ អនាគតំ អជាតំ អភូតំ អសញ្ជាតំ អនិព្វត្តំ អនភិនិព្វត្តំ អបាតុភូតំ នោ វត រេ វត្តព្វេ អនាគតេន សមន្នាគតោតិ ។

[៩២៥] អតីតេន រូបក្ខន្ធេន សមន្នាគតោ អនាគតេន រូបក្ខន្ធេន សមន្នាគតោ បច្ចុប្បន្នេន រូបក្ខន្ធេន សមន្នាគតោតិ ។ អាមន្តា ។ តីហិ រូបក្ខន្ធេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អតីតានាគតប្បច្ចុប្បន្នកថា

[៩២៣] បុគ្គល ប្រកបដោយអតីតឬ ។ អើ ។ គ្រែងអតីត រលត់ហើយ ទៅប្រាសហើយ ប្រែប្រួលហើយ អស់ហើយ បាត់ហើយ ឬ ។ អើ ។ ប្រសិនបើ អតីត រលត់ហើយ ទៅប្រាសហើយ ប្រែប្រួល ហើយ អស់ហើយ បាត់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រកបដោយអតីតទេ ។

[៩២៤] បុគ្គល ប្រកបដោយអនាគតឬ ។ អើ ។ គ្រែង អនាគត មិនទាន់កើត មិនទាន់មាន មិនទាន់លូតលាស់ មិនទាន់ដុះ មិនទាន់ដុះដាល មិនទាន់កើតប្រាកដទេឬ ។ អើ ។ ប្រសិនបើ អនាគត មិនទាន់កើត មិនទាន់មាន មិនទាន់លូតលាស់ មិនទាន់ដុះ មិនទាន់ដុះដាល មិនទាន់កើតប្រាកដទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរ ពោលថា បុគ្គល ប្រកបដោយអនាគតទេ ។

[៩២៥] បុគ្គល ប្រកបដោយរូបក្ខន្ធជាអតីត ប្រកបដោយ រូបក្ខន្ធជាអនាគត ប្រកបដោយរូបក្ខន្ធជាបច្ចុប្បន្នដែរឬ ។ អើ ។ មានតែ បុគ្គល ប្រកបដោយរូបក្ខន្ធ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អតីតេហិ បញ្ចហិ ខន្ធេហិ សមន្នាគតោ អនាគតេហិ បញ្ចហិ ខន្ធេហិ សមន្នាគតោ បច្ចុប្បន្នេហិ បញ្ចហិ ខន្ធេហិ សមន្នាគតោតិ ។ អាមន្តា ។ បន្នរសហិ ខន្ធេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩២៦] អតីតេន ចក្ខាយតនេន សមន្នាគតោ អនាគតេន ចក្ខាយតនេន សមន្នាគតោ បច្ចុប្បន្នេន ចក្ខាយតនេន សមន្នាគតោតិ ។ អាមន្តា ។ តីហិ ចក្ខាយតនេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អតីតេហិ ទ្វាទសហិ អាយតនេហិ សមន្នាគតោ អនាគតេហិ ទ្វាទសហិ អាយតនេហិ សមន្នាគតោ បច្ចុប្បន្នេហិ ទ្វាទសហិ អាយតនេហិ សមន្នាគតោតិ ។ អាមន្តា ។ ឆត្តឹសាយតនេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩២៧] អតីតាយ ចក្ខុធាតុយា សមន្នាគតោ អនាគតាយ ចក្ខុធាតុយា សមន្នាគតោ បច្ចុប្បន្នាយ ចក្ខុធាតុយា សមន្នាគតោតិ ។ អាមន្តា ។ តីហិ ចក្ខុធាតូហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បុគ្គល ប្រកបដោយខន្ធ ៥ ជាអតីត ប្រកបដោយខន្ធ ៥ ជាអនាគត ប្រកបដោយខន្ធ ៥ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយខន្ធ ១៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩២៦] បុគ្គល ប្រកបដោយចក្ខាយតនៈ ជាអតីត ប្រកបដោយចក្ខាយតនៈ ជាអនាគត ប្រកបដោយចក្ខាយតនៈ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយចក្ខាយតនៈ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលប្រកបដោយអាយតនៈ ១២ ជាអតីត ប្រកបដោយអាយតនៈ ១២ ជាអនាគត ប្រកបដោយអាយតនៈ ១២ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយអាយតនៈ ៣៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩២៧] បុគ្គល ប្រកបដោយចក្ខុធាតុ ជាអតីត ប្រកបដោយចក្ខុធាតុ ជាអនាគត ប្រកបដោយចក្ខុធាតុ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គលប្រកបដោយចក្ខុធាតុ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អតីតាហិ អដ្ឋារសហិ ធាតូហិ សមន្នាគតោ អនាគតាហិ អដ្ឋារសហិ ធាតូហិ សមន្នាគតោ បច្ចុប្បន្នាហិ អដ្ឋារសហិ ធាតូហិ សមន្នាគតោតិ ។ អាមន្តា ។ ចតុប្បញ្ញាសធាតូហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩២៨] អតីតេន ចក្ខុន្ទ្រិយេន សមន្នាគតោ អនាគតេន ចក្ខុន្ទ្រិយេន សមន្នាគតោ បច្ចុប្បន្នេន ចក្ខុន្ទ្រិយេន សមន្នាគតោតិ ។ អាមន្តា ។ តីហិ ចក្ខុន្ទ្រិយេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អតីតេហិ ពាវីសតិន្ទ្រិយេហិ សមន្នាគតោ អនាគតេហិ ពាវីសតិន្ទ្រិយេហិ សមន្នាគតោ បច្ចុប្បន្នេហិ ពាវីសតិន្ទ្រិយេហិ សមន្នាគតោតិ ។ អាមន្តា ។ ឆសដ្ឋិន្ទ្រិយេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩២៩] ន វត្តព្វំ អតីតានាគតេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អត្ថិ អដ្ឋវិមោក្ខឈាយី ចតុន្នំ ឈានានំ និកាមលាភី នវន្នំ អនុបុព្វវិហារសមាបត្តីនំ លាភីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ អដ្ឋវិមោក្ខឈាយី

បុគ្គល ប្រកបដោយធាតុ ១៨ ជាអតីត ប្រកបដោយធាតុ ១៨ ជាអនាគត ប្រកបដោយធាតុ ១៨ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយធាតុ ៥៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩២៨] បុគ្គល ប្រកបដោយចក្ខុន្ទ្រិយ ជាអតីត ប្រកបដោយចក្ខុន្ទ្រិយ ជាអនាគត ប្រកបដោយចក្ខុន្ទ្រិយ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយចក្ខុន្ទ្រិយ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយឥន្ទ្រិយ ២២ ជាអតីត ប្រកបដោយឥន្ទ្រិយ ២២ ជាអនាគត ប្រកបដោយឥន្ទ្រិយ ២២ ជាបច្ចុប្បន្នឬ ។ អើ ។ មានតែបុគ្គល ប្រកបដោយឥន្ទ្រិយ ៦៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩២៩] បុគ្គលមិនគួរនិយាយថា បុគ្គល ប្រកបដោយអតីតនិងអនាគតទេឬ ។ អើ ។ ក្រែងបុគ្គល ជាអ្នកចម្រើននូវវិមោក្ខ ៨ ជាអ្នកបានដោយមិនបាច់ប្រាថ្នា នូវឈានទាំង ៤ បាននូវអនុបុព្វវិហារសមាបត្តិទាំង ៩ មានឬ ។ អើ ។ ប្រសិនបើ បុគ្គល ជាអ្នកចម្រើននូវវិមោក្ខ ៨

៣៩៧

តស្ស ឧទ្ទានំ

ចតុន្នំ ឈានានំ និកាមលាភី នវន្នំ អនុបុព្វវិហារ-សមាបត្តីនំ លាភី តេន វត រេ វត្តព្វេ អតីតានាគត-តេហិ សមន្នាគតោតិ ។

អតីតានាគតប្បច្ចុប្បន្នកថា ។

នវមោ វគ្គោ ។

## តស្ស ឧទ្ទានំ

អានិសំសឧស្សាវិស្ស សញ្ញោជនានំ បហានំ អមតារម្មណំ សញ្ញោជនំ រូបំ សារម្មណំ អនុសយា អនារម្មណា ឯវមេវ ញាណំ អតី-តានាគតារម្មណំ ចិត្តំ សព្វំ ចិត្តំ វិតក្កានុ-បតិតំ សព្វសោ វិតក្កយតោ វិចារយតោ វិតក្កវិប្ផារោ សទ្ទោ នយថាចិត្តស្ស វាចា តថេវ កាយកម្មំ អតីតានាគតេហិ សមន្នាគតោតិ ។

ជាអ្នកបានដោយមិនបាច់ប្រាថ្នា នូវឈានទាំង ៤ បាននូវអនុបុព្វវិហារ-សមាបត្តិទាំង ៩ មាន (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល ប្រកបដោយអតីតនិងអនាគត ។

ចប់ អតីតានាគតបច្ចុប្បន្នកថា ។

ចប់ នវមវគ្គ ។

# ឧទ្ទាននៃនវមវគ្គនោះ គឺ

និយាយអំពី ការលះបង់ពួកសញ្ញោជនៈ របស់បុគ្គលអ្នកឃើញនូវអានិសង្ស ១ សញ្ញោជនៈ មានអមតៈ ជាអារម្មណ៍ ១ រូប ប្រកបដោយអារម្មណ៍ ១ ពួកអនុស័យ មិនមានអារម្មណ៍ ១ ញាណមិនមានអារម្មណ៍យ៉ាងនោះដែរ ១ ចិត្ត ជាអតីតារម្មណ៍ និងអនាគតារម្មណ៍ ១ ចិត្តទាំងអស់ មានវិតក្កៈជាប់តាម ១ សំឡេង ជាគ្រឿងផ្សាយចេញនៃវិតក្កៈ របស់បុគ្គលកាលត្រិះរិះ កាលពិចារណា ដោយសព្វគ្រប់ ១ វាចា របស់បុគ្គលមិនពោលតាមចិត្ត ១ កាយកម្ម របស់បុគ្គលមិនធ្វើតាមចិត្ត ដូច្នោះ ១ បុគ្គល ប្រកបដោយអតីតនិងអនាគត ១ ។

# និរោធកថា

[៩៣០] ឧបបត្តេសិយេ បញ្ចក្ខន្ធេ អនិរុទ្ធេ កិរិយា បញ្ច ខន្ធា ឧប្បជ្ជន្តីតិ ។ អាមន្តា ។ ទសន្នំ ខន្ធានំ សមោធានំ ហោតិ ទស ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទសន្នំ ខន្ធានំ សមោធានំ ហោតិ ទស ខន្ធា សម្មុខីភាវំ អាគច្ឆន្តី-តិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៣១] ឧបបត្តេសិយេ បញ្ចក្ខន្ធេ អនិរុទ្ធេ កិរិយា ចត្តារោ ខន្ធា ឧប្បជ្ជន្តីតិ ។ អាមន្តា ។ នវន្នំ ខន្ធានំ សមោធានំ ហោតិ នវ ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នវន្នំ ខន្ធានំ សមោធានំ ហោតិ នវ ខន្ធា សម្មុខីភាវំ អាគច្ឆន្តីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៣២] ឧបបត្តេសិយេ បញ្ចក្ខន្ធេ អនិរុទ្ធេ កិរិយា ញាណំ ឧប្បជ្ជតីតិ ។ អាមន្តា ។ ឆន្នំ ខន្ធានំ សមោធានំ ហោតិ ឆ ខន្ធា

# និរោធកថា

[៩៣០] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ខន្ធ ៥ ជាកិរិយា កើតឡើងឬ ។ អើ ។ ការប្រជុំ នៃខន្ធទាំង ១០ មាន ខន្ធទាំង ១០ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការប្រជុំ នៃខន្ធទាំង ១០ មាន ខន្ធទាំង ១០ មកកាន់ភាពចំពោះមុខឬ ។ អើ ។ ការប្រជុំ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៣១] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ខន្ធទាំង ៤ ជាកិរិយា កើតឡើងឬ ។ អើ ។ ការប្រជុំ នៃខន្ធទាំង ៩ មាន ខន្ធទាំង ៩ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការប្រជុំ នៃខន្ធទាំង ៩ មាន ខន្ធទាំង ៩ មកកាន់ភាពចំពោះមុខឬ ។ អើ ។ ការប្រជុំ នៃផស្សៈ ទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៣២] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត មិនទាន់រលត់ ញាណ ជាកិរិយា កើតឡើងឬ ។ អើ ។ ការប្រជុំ នៃខន្ធទាំង ៦ មាន ខន្ធទាំង ៦

សម្មុទីការំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឆន្ទំ ខន្ធានំ សមោធានំ ហោតិ ឆ ខន្ធា សម្មុទីការំ អាគច្ឆន្តីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៣៣] ឧបបត្តេសិយេ បញ្ចក្ខន្ធេ និរុទ្ធេ មគ្គោ ឧប្បជ្ជតីតិ ។ អាមន្តា ។ មតោ មគ្គំ ភាវេតិ កាលកតោ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

និរោធកថា ។

# រូបំ មគ្គោតិកថា

[៩៣៤] មគ្គសមង្គិស្ស រូបំ មគ្គោតិ ។ អាមន្តា ។ សារម្មណំ អត្ថិ តស្ស អាវជ្ជនា អាភោគោ សមន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណំ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ មគ្គសមង្គិស្ស រូបំ មគ្គោតិ ។

មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការប្រជុំ នៃខន្ធទាំង ៦ មាន ខន្ធទាំង ៦ មកកាន់ភាពចំពោះមុខឬ ។ អើ ។ ការប្រជុំ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៣៣] កាលបញ្ចក្ខន្ធ ស្វែងរកកំណើត រលត់ហើយ មគ្គកើតឡើងឬ ។ អើ ។ បុគ្គលស្លាប់ ទើបចម្រើនមគ្គ បុគ្គលធ្វើមរណៈកាល ទើបចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ និរោធកថា ។

# រូបមគ្គោតិកថា

[៩៣៤] រូប របស់បុគ្គលព្រមព្រៀងដោយមគ្គ ជាមគ្គឬ ។ អើ ។ រូប ប្រកបដោយអារម្មណ៍ ការពិចារណា ការសង្ឃឹម ការប្រមូលមក ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងចិត្តទុកចំពោះរូបនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងរូប មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ រូប មិនមានអារម្មណ៍ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប របស់បុគ្គលព្រមព្រៀងដោយមគ្គ ជាមគ្គទេ ។

[៩៣៥] សម្មាវាចា មគ្គោតិ ។ អាមន្តា ។ សារម្មណា អត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណា នត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណា នត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ សម្មាវាចា មគ្គោតិ ។

[៩៣៦] សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោតិ ។ អាមន្តា ។ សារម្មណោ អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណោ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណោ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ សម្មាអាជីវោ មគ្គោតិ ។

[៩៣៧] សម្មាទិដ្ឋិ មគ្គោ សា ច សារម្មណា អត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។

[៩៣៥] សម្មាវាចា ជាមគ្គឬ ។ អើ ។ (សម្មាវាចា) ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសម្មាវាចា មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ (សម្មាវាចា) មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សម្មាវាចា ជាមគ្គទេ ។

[៩៣៦] សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គឬ ។ អើ ។ (សម្មាអាជីវៈ) ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសម្មាអាជីវៈ មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ សម្មាអាជីវៈ មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សម្មាអាជីវៈ ជាមគ្គទេ ។

[៩៣៧] សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។បេ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មានឬ។

អាមន្តា ។ សម្មាវាចា មគ្គោ សា ច សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ មគ្គោ សា ច សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោ សោ ច សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយាមោ ។ បេ ។ សម្មាសតិ ។ បេ ។

[៩៣៨] សម្មាសមាធិ មគ្គោ សោ ច សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាវាចា មគ្គោ សា ច សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាសមាធិ មគ្គោ សោ ច សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោ សោ ច

អើ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មានឬ ។ អើ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។

[៩៣៨] សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មានឬ ។ អើ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មានឬ ។ អើ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង

សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៣៩] សម្មាវាចា មគ្គោ សា ច អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាទិដ្ឋិ មគ្គោ សា ច អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាវាចា មគ្គោ សា ច អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយាមោ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គោ សោ ច អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៤០] សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គោ សោ ច អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសង្កប្បោ សម្មាវាយាមោ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គោ សោ ច អនារម្មណោ នត្ថិ តស្ស អាវជ្ជនា

ប្រកបដោយអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៣៩] សម្មាវាចា ជាមគ្គ សម្មាវាចា នោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ សម្មាទិដ្ឋិ ជាមគ្គ សម្មាទិដ្ឋិនោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាទិដ្ឋិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាវាចា ជាមគ្គ សម្មាវាចានោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាវាចានោះ មិនមានទេឬ ។ អើ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៤០] សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាមគ្គ សម្មាអាជីវៈនោះឯង មិនមានអារម្មណ៍ ការពិចារណា ។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាអាជីវៈនោះ មិនមានទេឬ ។ អើ ។ សម្មាទិដ្ឋិ ។ បេ ។ សម្មាសង្កប្បៈ សម្មាវាយាមៈ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាមគ្គ សម្មាសមាធិនោះឯង មិនមានអារម្មណ៍ ការពិចារណា

។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៤១] ន វត្តព្វំ មគ្គសមង្គិស្ស រូបំ មគ្គោតិ ។ អាមន្តា ។ ននុ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ មគ្គោតិ ។ អាមន្តា ។ ហញ្ចិ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ មគ្គោ តេន វត វេ វត្តព្វេ មគ្គសមង្គិស្ស រូបំ មគ្គោតិ ។

រូបំ មគ្គោតិកថា ។

# បញ្ចវិញ្ញាណសមង្គិស្ស មគ្គភាវនាកថា

[៩៤២] បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា នោ វត វេ វត្តព្វេ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។

[៩៤៣] ននុ បញ្ចវិញ្ញាណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុកា ពាហិរារម្មណា

។ បេ ។ ការតាំងចិត្តទុក ចំពោះសម្មាសមាធិនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៤១] បុគ្គលមិនគួរនិយាយថា រូប របស់បុគ្គលដែលព្រមព្រៀង ដោយមគ្គ ជាមគ្គទេឬ ។ អើ ។ ក្រែងសម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជាមគ្គឬ ។ អើ ។ ប្រសិនបើ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ជាមគ្គ (យ៉ាងនេះ) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប របស់បុគ្គលដែលព្រមព្រៀង ដោយមគ្គ ជាមគ្គ ។

ចប់ រូបមគ្គោតិកថា ។

# បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា

[៩៤២] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានឬ ។ អើ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានទេ ។

[៩៤៣] ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងមុន មានអារម្មណ៍កើតឡើងមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ

អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណា ជាជាវត្ថុកា ជាជា-
រម្មណា ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ន
អសមន្នាហារា ឧប្បជ្ជន្តិ ន អមនសិការា ឧប្បជ្ជន្តិ
ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ន
អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តិ ។ បេ ។ ននុ បញ្ច-
វិញ្ញាណា អនាភោគាតិ ។ អាមន្តា ។ ហញ្ចិ បញ្ច-
វិញ្ញាណា អនាភោគា នោ វត រេ វត្តព្វេ បញ្ចវិញ្ញា-
ណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។

[៩៤៤] ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា-
តិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតី-
តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុវិញ្ញាណំ សុញ្ញតំ
អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច
ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។
ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។
អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុ-
វិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច
រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។

មានវត្ថុមិនប្រទាំគ្នា មានអារម្មណ៍មិនប្រទាំគ្នា មានវត្ថុផ្សេងៗគ្នា មានអារម្មណ៍ផ្សេងៗគ្នា មិនទទួល នូវគោចរវិស័យ របស់គ្នានិងគ្នាមិនកើតឡើង អំពីការមិនប្រមូលមក មិនកើតឡើង អំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើង អំពីការមិនប្រឡូកប្រទាំគ្នា មិនកើតឡើងមិនមុន មិនក្រោយ មិនកើតឡើងក្នុងលំដាប់ស្មើនៃគ្នានិងគ្នា ។ បេ ។ ក្រែងបញ្ចវិញ្ញាណ មិនមានការពិចារណាទេឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនមានការពិចារណាទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានទេ ។

[៩៤៤] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុ-វិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ ណោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

[៩៤៥] ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវ-ជាតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុវិញ្ញាណស-មង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ វេទនំ អារព្ភ សញ្ញំ អារព្ភ ចេតនំ អារព្ភ ចិត្តំ អារព្ភ ចក្ខុំ អារព្ភ ។ បេ ។ កាយំ អារព្ភ សទ្ទំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា មនោវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា មនោវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុ-វិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ

អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងទេ ។

[៩៤៥] មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុ-វិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ប្រារព្ធវេទនា ប្រារព្ធសញ្ញា ប្រារព្ធចេតនា ប្រារព្ធចិត្ត ប្រារព្ធចក្ខុ ។ បេ ។ ប្រារព្ធកាយ ប្រារព្ធសំឡេង ។ បេ ។ ប្រារព្ធផោ-ដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គភា-វនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោ-វិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អើ ។ មគ្គភា-វនា របស់បុគ្គលដែលព្រមព្រៀងដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ

។ បេ ។ មនោវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា មនោវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនា ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ផោ-ដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៤៦] ន វត្តព្វំ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខ-វេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី ។ បេ ។ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហីតិ អត្ថេវ សុត្ត-ន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចវិញ្ញាណសមង្គិស្ស អត្ថិ មគ្គភាវនាតិ ។

បញ្ចវិញ្ញាណសមង្គិស្ស មគ្គភាវនាកថា ។

## បញ្ចវិញ្ញាណា កុសលាបីតិកថា

[៩៤៧] បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។

។ បេ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយមនោវិញ្ញាណ មាន ឯមនោវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អើ ។ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយចក្ខុវិញ្ញាណ មាន ឯចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៤៦] បុគ្គលមិនគួរនិយាយថា មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ឃើញរូប ដោយចក្ខុ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ។ បេ ។ ឮសំឡេង ដោយត្រចៀក ។ បេ ។ ធុំក្លិន ដោយច្រមុះ ។ បេ ។ លិទ្ធរស ដោយអណ្តាត ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គភាវនា របស់បុគ្គលដែលព្រមព្រៀង ដោយបញ្ចវិញ្ញាណ មាន ។

ចប់ បញ្ចវិញ្ញាណសមង្គិមគ្គភាវនាកថា ។

# បញ្ចវិញ្ញាណា កុសលាបីតិកថា

[៩៤៧] បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។

អាមន្តា ។ ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នា-
រម្មណាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ឧប្បន្ន-
វត្ថុកា ឧប្បន្នារម្មណា នោ វត រេ វត្តព្វេ បញ្ចវិញ្ញា-
ណា កុសលាបិ អកុសលាបីតិ ។ ននុ បញ្ចវិញ្ញា-
ណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុ-
កា ពាហិរារម្មណា អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណា
នានាវត្ថុកា នានារម្មណា ន អញ្ញមញ្ញស្ស គោចរវិ-
សយំ បច្ចនុភោន្តិ ន អសមន្នាហារា ឧប្បជ្ជន្តិ ន អ-
មនសិការា ឧប្បជ្ជន្តិ ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន
អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ន អញ្ញមញ្ញស្ស សមនន្តរា
ឧប្បជ្ជន្តិ ននុ បញ្ចវិញ្ញាណា អនាភោគាតិ ។ អាមន្តា ។
ហញ្ចិ បញ្ចវិញ្ញាណា អនាភោគា នោ វត រេ វត្តព្វេ
បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។

[៩៤៨] ចក្ខុវិញ្ញាណំ កុសលន្តិ ។ អាមន្តា ។
ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាម-
ន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ

អើ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានទេ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតមុន មានអារម្មណ៍កើតមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រទ្បាំគ្នា មានអារម្មណ៍មិនប្រទ្បាំគ្នា មានវត្ថុផ្សេងៗគ្នា មានអារម្មណ៍ផ្សេងៗគ្នា មិនទទួលនូវគោចរវិស័យនៃគ្នានិងគ្នា មិនកើតឡើង អំពីការមិនពិចារណា មិនកើតឡើងអំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើង អំពីការមិនប្រទ្បូកប្រទ្បាំគ្នា មិនកើតឡើងមិនមុនមិនក្រោយ មិនកើតឡើង ក្នុងលំដាប់ស្មើ នៃគ្នានិងគ្នា ក្រែង បញ្ចវិញ្ញាណ មិនមានកំណត់ទុកក្នុងចិត្តទេឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនមានកំណត់ទុកក្នុងចិត្ត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានទេ ។

[៩៤៨] ចក្ខុវិញ្ញាណ ជាកុសលឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ នោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

[៩៤៩] ចក្ខុវិញ្ញាណំ កុសលម្បិ អកុសលម្បីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុវិញ្ញាណំ កុសលម្បិ អកុសលម្បីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ចិត្តំ អារព្ភ ។ បេ ។ ចក្ខុំ អារព្ភ ។ បេ ។ កាយំ អារព្ភ ។ បេ ។ សទ្ទំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ កុសលម្បិ

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិង សភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិង សភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិន មានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុ និងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើប កើតឡើងទេ ។

[៩៤៩] ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជា អកុសលក៏មានឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធចិត្ត ។ បេ ។ ប្រារព្ធចក្ខុ ។ បេ ។ ប្រារព្ធកាយ ។ បេ ។ ប្រារព្ធសំឡេង ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នក មិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ជាកុសលក៏មាន

អកុសលម្បិ មនោវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជ-
តីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ កុសលម្បិ អកុ-
សលម្បិ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ កុសលម្បិ
អកុសលម្បិ មនោវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្ប-
ជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ កុសលម្បិ អកុ-
សលម្បិ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជ-
តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ កុ-
សលម្បិ អកុសលម្បិ មនោវិញ្ញាណំ ផស្សំ អារព្ភ
។ បេ ។ ចិត្តំ អារព្ភ ចក្ខុំ អារព្ភ ។ បេ ។ កាយំ
អារព្ភ សទ្ទំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្ប-
ជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ កុសលម្បិ
អកុសលម្បិ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។
ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩៤០] ន វត្តព្វំ បញ្ចវិញ្ញាណា កុសលាបិ
អកុសលាបីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា
ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី
ហោតិ ។ បេ ។ ន និមិត្តគ្គាហី ហោតិ ។ បេ ។

ជាអកុសលក៏មាន ឯមនោវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើង ឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯមនោ-វិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯចក្ខុវិញ្ញាណ ប្រារព្ធ អតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯមនោ-វិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធចិត្ត ប្រារព្ធចក្ខុ ។ បេ ។ ប្រារព្ធកាយ ប្រារព្ធសំឡេង ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើង ឬ ។ អើ ។ ចក្ខុវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ឯ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើង ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៥០] បុគ្គលមិនគួរនិយាយថា បញ្ចវិញ្ញាណ ជាកុសលក៏ មាន ជាអកុសលក៏មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ឃើញរូបដោយ ចក្ខុ ជាអ្នកកាន់យកនូវនិមិត្ត ។បេ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ។បេ។

សោតេន សទ្ទំ សុត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា និមិត្តគ្គាហី ហោតីតិ ។ បេ ។ ន និមិត្តគ្គាហី ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចវិញ្ញាណា កុសលាបិ អកុសលាបីតិ ។

បញ្ចវិញ្ញាណា កុសលាបីតិកថា ។

## បញ្ចវិញ្ញាណា សាភោគាតិកថា

[៩៤១] បញ្ចវិញ្ញាណា សាភោគាតិ ។ អាមន្តា ។ ននុ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណាតិ ។ អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ឧប្បន្នវត្ថុកា ឧប្បន្នារម្មណា នោ វត រេ វត្តព្វេ បញ្ចវិញ្ញាណា សាភោគាតិ ។ បេ ។ ននុ បញ្ចវិញ្ញាណា បុរេជាតវត្ថុកា បុរេជាតារម្មណា អជ្ឈត្តិកវត្ថុកា ពាហិរារម្មណា អសម្ភិន្នវត្ថុកា អសម្ភិន្នារម្មណា នានាវត្ថុកា នានារម្មណា ន អញ្ញមញ្ញស្ស គោចរវិសយំ បច្ចនុភោន្តិ ន អសមន្នាហារា ឧប្បជ្ជន្តិ ន អមនសិការា ឧប្បជ្ជន្តិ ន អព្វោកិណ្ណា ឧប្បជ្ជន្តិ ន អបុព្វំ អចរិមំ ឧប្បជ្ជន្តិ ននុ បញ្ចវិញ្ញាណា ន អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តីតិ ។

ឮសំឡេងដោយត្រចៀក ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ជាអ្នកកាន់យកនូវនិមិត្ត ។ បេ ។ ជាអ្នកមិនកាន់យកនូវនិមិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បញ្ចវិញ្ញាណ ជាកុសលក៏មាន ជាអកុសលក៏មាន ។

ចប់ បញ្ចវិញ្ញាណា កុសលាបីតិកថា ។

## បញ្ចវិញ្ញាណា សាភោគាតិកថា

[៩៤១] បញ្ចវិញ្ញាណ ប្រកបដោយការសង្ស័យឬ ។ អើ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយឬ ។ អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មានវត្ថុកើតឡើងហើយ មានអារម្មណ៍កើតឡើងហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ប្រកបដោយការសង្ស័យទេ ។ បេ ។ ក្រែងបញ្ចវិញ្ញាណ មានវត្ថុកើតមុន មានអារម្មណ៍កើតមុន មានវត្ថុប្រព្រឹត្តទៅខាងក្នុង មានអារម្មណ៍ខាងក្រៅ មានវត្ថុមិនប្រទាំគ្នា មានអារម្មណ៍មិនប្រទាំគ្នា មានវត្ថុផ្សេងៗ គ្នា មានអារម្មណ៍ផ្សេង ។ គ្នា មិនទទួលនូវគោចរវិស័យនៃគ្នានិងគ្នា មិនកើតឡើង អំពីការមិនពិចារណា មិនកើតឡើង អំពីការមិនធ្វើទុកក្នុងចិត្ត មិនកើតឡើង អំពីការមិនប្រឡូកប្រទាំគ្នា មិនមែនកើតឡើង មិនមុនមិនក្រោយ ក្រែងបញ្ចវិញ្ញាណ មិនកើតឡើង ក្នុងលំដាប់ស្មើ នៃគ្នានិងគ្នាទេឬ ។

អាមន្តា ។ ហញ្ចិ បញ្ចវិញ្ញាណា ន អញ្ញមញ្ញស្ស សមនន្តរា ឧប្បជ្ជន្តិ នោ វត រេ វត្តព្វេ បញ្ចវិញ្ញាណា សាភោគាតិ ។

[៩៤២] ចក្ខុវិញ្ញាណំ សាភោគន្តិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។ អាមន្តា ។ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ នត្ថិ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ អត្ថេវ សុត្តន្តោ នោ វត រេ វត្តព្វេ ចក្ខុញ្ច បដិច្ច សុញ្ញតញ្ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណន្តិ ។

[៩៤៣] ចក្ខុវិញ្ញាណំ សាភោគន្តិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន

អើ ។ ប្រសិនបើ បញ្ចវិញ្ញាណ មិនកើតឡើង ក្នុងលំដាប់ស្មើ នៃគ្នានិងគ្នាទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បញ្ចវិញ្ញាណ ប្រកបដោយការសង្ឃឹមទេ ។

[៩៥២] ចក្ខុវិញ្ញាណ ប្រកបដោយការសង្ឃឹមឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ មិនមានទេ ។ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ប្រសិនបើ ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងរូប ទើបកើតឡើង ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចក្ខុវិញ្ញាណ អាស្រ័យចក្ខុនិងសភាវៈសូន្យ ទើបកើតឡើងទេ ។

[៩៥៣] ចក្ខុវិញ្ញាណ ប្រកបដោយការសង្ឃឹមឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរ

ហេវំ វត្តព្វេ ។ បេ ។ ចក្ខុវិញ្ញាណំ សាភោគន្តិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ សាភោគំ មនោវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ សាភោគំ ចក្ខុវិញ្ញាណំ សុញ្ញតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ សាភោគំ មនោវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ សាភោគំ ចក្ខុវិញ្ញាណំ អតីតានាគតំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនោវិញ្ញាណំ សាភោគំ មនោវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ សាភោគំ ចក្ខុវិញ្ញាណំ ផស្សំ អារព្ភ ។ បេ ។ ផោដ្ឋព្វំ អារព្ភ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពោលយ៉ាងនេះទេ ។ បេ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្ស័យ ឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោ-វិញ្ញាណ ប្រកបដោយការសង្ស័យ មនោវិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្ស័យ ចក្ខុ-វិញ្ញាណ ប្រារព្ធសភាវៈសូន្យ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ប្រកបដោយការសង្ស័យ មនោ-វិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អើ ។ ចក្ខុ-វិញ្ញាណ ប្រកបដោយការសង្ស័យ ចក្ខុវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ប្រកបដោយការសង្ស័យ មនោវិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្ស័យ ចក្ខុ-វិញ្ញាណ ប្រារព្ធអតីតនិងអនាគត ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនោវិញ្ញាណ ប្រកបដោយការសង្ស័យ មនោវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អើ ។ ចក្ខុវិញ្ញាណ ប្រកបដោយការសង្ស័យ ចក្ខុវិញ្ញាណ ប្រារព្ធផស្សៈ ។ បេ ។ ប្រារព្ធផោដ្ឋព្វៈ ទើបកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩៩៤] ន វត្តព្វំ បញ្ចវិញ្ញាណា សាភោគាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ ។ បេ ។ ន និមិត្តគ្គាហី ហោតិ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា និមិត្តគ្គាហី ហោតិ ។ បេ ។ ន និមិត្តគ្គាហី ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ បញ្ចវិញ្ញាណា សាភោគាតិ ។ បេ ។

បញ្ចវិញ្ញាណា សាភោគាតិកថា ។

# ទ្វីហិ សីលេហិ សមន្នាគតោតិកថា

